**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**គណៈកម្មការមូលបត្រកម្ពុជា**
លេខៈ...០០៣/១៨...គ.ម.ក./ប្រ.ក.

# ប្រកាស
# ស្តីពី
# ការផ្តល់អាជ្ញាបណ្ណ និងការគ្រប់គ្រងអាជីវកម្មគម្រោងវិនិយោគរួម

## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
## និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹតលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៧/០០១ ចុះថ្ងៃទី១០ ខែមករា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីមូលបត្ររដ្ឋ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១០០៧/០២៨ ចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន
- បានឃើញអនុក្រឹត្យលេខ ៩៧ អនក្រ.បក ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០០៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការមូលបត្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០០៩ ស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន

- យោងតាមការអនុម័តនៃសម័យប្រជុំពេញអង្គរបស់គណៈកម្មការមូលបត្រកម្ពុជា នាថ្ងៃទី០៨ ខែឧសភា ឆ្នាំ ២០១៨

## ស ម្រេ ច

## ជំពូកទី ១
## បទប្បញ្ញត្តិទូទៅ

### ប្រការ ១.- គោលបំណង

ប្រកាសនេះមានគោលបំណងគ្រប់គ្រងរាល់ប្រតិបត្តិការកៀរគរមូលធនពីសាធារណជន នៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈគម្រោងវិនិយោគរួម និងបុគ្គលពាក់ព័ន្ធឱ្យមានប្រសិទ្ធភាព តម្លាភាព គណនេយ្យភាព សណ្តាប់ធ្នាប់ និងរបៀបរៀបរយ។

### ប្រការ ២.- គោលដៅ

ប្រកាសនេះមានគោលដៅកំណត់ពីលក្ខខណ្ឌ និងនីតិវិធីក្នុងការផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត និងផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាតបន្ត និងកំណត់ពីកាតព្វកិច្ចផ្សេងៗរបស់ក្រុមហ៊ុនដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើអាជីវកម្មគម្រោងវិនិយោគរួម និងភ្នាក់ងារទទួលបានអាជ្ញាបណ្ណពីគណៈកម្មការមូលបត្រកម្ពុជា (**គ.ម.ក.**) ព្រមទាំងបុគ្គលពាក់ព័ន្ធ។

### ប្រការ ៣.- វិសាលភាព

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះប្រតិបត្តិការកៀរគរមូលធនពីសាធារណជននៅក្នុងព្រះរាជាណាចក្រកម្ពុជាតាមរយៈគម្រោងវិនិយោគរួម និងបុគ្គលពាក់ព័ន្ធនឹងប្រតិបត្តិការនេះ។

### ប្រការ ៤.- និយមន័យ

និយមន័យនៃពាក្យបច្ចេកទេសដែលប្រើប្រាស់ក្នុងប្រកាសនេះត្រូវបានកំណត់ក្នុងប្រការនេះ និងមាននៅក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃច្បាប់ស្តីពីការបោះផ្សាយនិងការជួញដូរមូលបត្រមហាជន និងអនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ការផ្តល់មុខងារទៅបុគ្គលខាងក្រៅ** (Outsourcing)÷ ការផ្តល់មុខងារមួយចំនួនពីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត ទៅអ្នកផ្តល់សេវាកម្មខាងក្រៅ ឬអ្នកចុះកិច្ចសន្យាបន្ត តាមរយៈកិច្ចសន្យា ហើយការផ្តល់មុខងារទៅបុគ្គលខាងក្រៅនេះត្រូវទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

**ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត**÷ សំដៅដល់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង និងក្រុមហ៊ុនអភិបាលមូលនិធិដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

**ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ** (Fund Management Company)÷ សំដៅដល់បុគ្គលគ្រប់គ្រងមូលនិធិជានីតិបុគ្គលដែលត្រូវទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីធ្វើអាជីវកម្មដូចមានកំណត់ក្នុងអនុក្រឹត្យ និងប្រកាសនេះ។

**ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង** (Distribution Company)÷ សំដៅដល់ក្រុមហ៊ុនដែលត្រូវទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីធ្វើអាជីវកម្មចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សងដូចមានកំណត់ក្នុងអនុក្រឹត្យ និងប្រកាសនេះ។

**គម្រោងវិនិយោគរួម** (Collective Investment Scheme)÷ សំដៅដល់គម្រោងវិនិយោគដែលត្រូវទទួលបានការអនុញ្ញាតពី **គ.ម.ក.** និងមានលក្ខណៈដូចខាងក្រោម÷

១-ការប្រមូលសាច់ប្រាក់ ឬវត្ថុមានតម្លៃតាមរយៈការបោះផ្សាយលក់ឯកតាមូលនិធិ ឬតាមរយៈប្រព័ន្ធអេឡិចត្រូនិច ប្លុករួមទាំងក្រោជហ្វាន់ឌីង ឬតាមទម្រង់ផ្សេងទៀតដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.** ដើម្បីបង្កើតមូលនិធិសាធារណៈ មូលនិធិឯកជន ឬបរធនវិនិយោគអចលនវត្ថុ ដូចដែលកំណត់ក្នុងប្រកាសនេះ។

២-រាល់សាច់ប្រាក់ ឬវត្ថុមានតម្លៃដែលប្រមូលបាន ត្រូវបានយកទៅប្រើប្រាស់ និងចាត់ចែងដោយក្រុមហ៊ុនគ្រប់គ្រងមូលនិធិនៅក្នុងគម្រោងវិនិយោគរួម ដើម្បីបង្កើតផលកម្រៃហិរញ្ញវត្ថុ ឬផលកម្រៃដែលបានមកជាសិទ្ធិ ឬជាផលប្រយោជន៍លើទ្រព្យសម្បត្តិ សម្រាប់សមាជិកដែលមានផលប្រយោជន៍ក្នុងគម្រោងវិនិយោគនោះ ទោះបីសមាជិកនោះមិនគ្រប់គ្រងលើប្រតិបត្តិការប្រចាំថ្ងៃនៃគម្រោងវិនិយោគនោះក៏ដោយ។

៣-ទ្រព្យសម្បត្តិរបស់គម្រោងវិនិយោគរួមត្រូវរក្សាទុកដោយក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសដែលធ្វើប្រតិបត្តិការក្នុងនាមគម្រោងវិនិយោគរួម។

៤-គម្រោងវិនិយោគរួមអាចជាមូលនិធិបើក ឬមូលនិធិបិទ។

៥-គម្រោងវិនិយោគរួមអាចត្រូវបានគ្រប់គ្រងក្នុងទម្រង់ជាកិច្ចសន្យា ឬជាក្រុមហ៊ុន។

**ទ្រព្យសម្បត្តិបរធនវិនិយោគ** (Investment Trust Property)÷ សំដៅដល់ទ្រព្យសម្បត្តិ ឬមូលនិធិនៃគម្រោងវិនិយោគរួមដែលត្រូវបានកាន់កាប់ និងគ្រប់គ្រងដោយក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសក្នុងនាមអគ្គតាហកៈ តាមលក្ខខណ្ឌដែលបានកំណត់នៅក្នុងកិច្ចព្រមព្រៀងបរធនបាលកិច្ច និង/ឬច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

**បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ**÷ សំដៅដល់អភិបាល សហកម្មសិទ្ធិករ នាយកប្រតិបត្តិ សមាជិកគណៈកម្មាធិការវិនិយោគ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករជំនាញមូលធិនិ ដែលទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ក.**។

**បុគ្គលមានទំនាក់ទំនងពិសេស** (Specially-Related Person)÷ សំដៅដល់បុគ្គលដូចខាងក្រោម÷

១-ករណីបុគ្គលដើមជារូបវន្តបុគ្គល បុគ្គលដែលមានទំនាក់ទំនងពិសេសអាចជា៖

ក- សហព័ទ្ធ។

ខ- សាខាញាតិលោហិតរហូតដល់ថ្នាក់ទី ៤។

គ- ខ្សែផ្ទាល់នៃបុព្វញាតិ ឬបច្ឆាញាតិរហូតដល់ថ្នាក់ទី ៣។

ឃ- សាខាញាតិពន្ធរហូតដល់ថ្នាក់ទី ៣។

ង- ខ្សែផ្ទាល់នៃបុព្វញាតិ ឬបច្ឆាញាតិរបស់បុគ្គលដែលចូលក្នុងគ្រួសាររបស់បុគ្គលដើមក្នុងនាមជាកូនចិញ្ចឹម និងសហព័ន្ធរបស់បុគ្គលនោះ។

ច- បុគ្គលដែលរស់នៅដោយពឹងផ្អែកលើប្រាក់ ឬទ្រព្យសម្បត្តិរបស់បុគ្គលដើម និងបុគ្គលដែលរួមរស់ជាមួយបុគ្គលដើម។

ឆ- ក្រុមហ៊ុនណាមួយដែលក្នុងនោះបុគ្គលដើមធ្វើការវិនិយោគ ៣០ (សាមសិប) ភាគរយ ឬលើសពីនេះតែម្នាក់ឯង ឬដោយចូលរួមជាមួយបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងចំណុច (ក) រហូតដល់ (ច) នៃចំណុចទី ១ ខាងលើនេះ ឬបុគ្គលដើមមានឥទ្ធិពលលើបញ្ហាសំខាន់នៃការគ្រប់គ្រងដូចជាការតែងតាំង ឬការបណ្តេញចេញនាយកប្រតិបត្តិរបស់ក្រុមហ៊ុននោះ ឬក្រុមហ៊ុនពាក់ព័ន្ធ។

ជ- ក្រុមហ៊ុនណាមួយដែលក្នុងនោះបុគ្គលដើមធ្វើការវិនិយោគ ៣០ (សាមសិប) ភាគរយ ឬលើសពីនេះតែម្នាក់ឯង ឬដោយចូលរួមជាមួយបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងចំណុច (ក) រហូតដល់ (ឆ) នៃចំណុចទី ១ ខាងលើនេះ ឬបុគ្គលដើមមានឥទ្ធិពលលើបញ្ហាសំខាន់នៃការគ្រប់គ្រងដូចជា ការតែងតាំង ឬការបណ្តេញចេញនាយកប្រតិបត្តិរបស់ក្រុមហ៊ុននោះ ឬក្រុមហ៊ុនពាក់ព័ន្ធ។

២-ករណីបុគ្គលដើមជាក្រុមហ៊ុន បុគ្គលដែលមានទំនាក់ទំនងពិសេសអាចជា៖

ក- នាយកប្រតិបត្តិ អភិបាល ឬសហកម្មសិទ្ធិករ។

ខ- សាខាក្រុមហ៊ុន អភិបាល ឬសហកម្មសិទ្ធិកររបស់សាខាក្រុមហ៊ុននោះ។

គ- រូបវន្តបុគ្គលដែលវិនិយោគ ៣០ (សាមសិប) ភាគរយ ឬលើសពីនេះក្នុងបុគ្គលដើមតែម្នាក់ឯង ឬដោយចូលរួមជាមួយបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងចំណុចទី ១ ខាងលើ ឬរូបវន្តបុគ្គលនេះមានឥទ្ធិពលលើបញ្ហាសំខាន់នៃការគ្រប់គ្រងដូចជាការតែងតាំង ឬការបណ្តេញចេញនាយកប្រតិបត្តិរបស់បុគ្គលដើម។

ឃ- ក្រុមហ៊ុនណាមួយដែលក្នុងនោះបុគ្គលដើមធ្វើការវិនិយោគ ៣០ (សាមសិប) ភាគរយ ឬលើសពីនេះតែម្នាក់ឯង ឬដោយចូលរួមជាមួយបុគ្គលពាក់ព័ន្ធដូចមានចែងក្នុងចំណុច (ក) រហូតដល់ (គ) នៃចំណុចទី ២ ខាងលើនេះ ឬបុគ្គលដើមនេះមានឥទ្ធិពលលើបញ្ហាសំខាន់នៃការគ្រប់គ្រងដូចជាការតែងតាំង ឬការបណ្តេញចេញនាយកប្រតិបត្តិរបស់ក្រុមហ៊ុន ឬក្រុមហ៊ុនពាក់ព័ន្ធ។

**បរធនវិនិយោគអចលនវត្ថុ** (Real Estate Investment Trust)៖ សំដៅដល់គម្រោងវិនិយោគរួមដែលត្រូវបានប្រើប្រាស់ដើម្បីវិនិយោគលើអចលនវត្ថុដែលអាចផ្តល់ប្រាក់ចំណូល អនុលោមតាមច្បាប់ស្តីពីការ

បោះផ្សាយ និងការជួញដូរមូលបត្រមហាជន និងបទប្បញ្ញត្តិជាធរមាន។

**ប្រាក់តម្កល់ធានាអាជីវកម្ម**÷ សំដៅដល់ចំនួនសាច់ប្រាក់ដែលក្រុមហ៊ុនត្រូវដាក់តម្កល់សម្រាប់ជាប្រាក់ធានាដែលត្រូវយកមកប្រើប្រាស់ដើម្បីបំពេញកាតព្វកិច្ចហិរញ្ញវត្ថុក្នុងករណីដែលក្រុមហ៊ុនបញ្ចប់អាជីវកម្ម។

**ភ្នាក់ងារក្រោដហ្វាន់ឌីង** (Crowdfunding Representative)÷ សំដៅដល់រូបវន្តបុគ្គលដែលត្រូវទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីផ្តល់សេវា និងធ្វើសកម្មភាពអាជីវកម្មក្នុងនាមក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលធ្វើអាជីវកម្មដូចមានកំណត់ក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ។

**ភ្នាក់ងារចែកចាយលក់មូលនិធិ** (Fund Selling Representative)÷ សំដៅដល់រូបវន្តបុគ្គលដែលត្រូវទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីផ្តល់សេវា និងធ្វើសកម្មភាពក្នុងនាមក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ដូចមានកំណត់ក្នុងអនុក្រឹត្យ និងប្រកាសនេះ។

**ភ្នាក់ងារគ្រប់គ្រងមូលនិធិ** (Fund Management Representative)÷ សំដៅដល់បុគ្គលគ្រប់គ្រងមូលនិធិជារូបវន្តបុគ្គល ដែលត្រូវទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ដើម្បីផ្តល់សេវា និងធ្វើសកម្មភាពអាជីវកម្មក្នុងនាមក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលធ្វើអាជីវកម្មដូចមានកំណត់ក្នុងអនុក្រឹត្យ និងប្រកាសនេះ។

**ភ្នាក់ងារទទួលបានអាជ្ញាបណ្ណ**÷ សំដៅដល់ភ្នាក់ងារគ្រប់គ្រងមូលនិធិ ភ្នាក់ងារក្រោដហ្វាន់ឌីង និងភ្នាក់ងារចែកចាយលក់មូលនិធិ ដែលទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.**។

**មូលនិធិសាធារណៈ** (Public Fund)÷ សំដៅដល់មូលនិធិនៃគម្រោងវិនិយោគរួមដែលបានបោះផ្សាយលក់ឯកតាមូលនិធិដល់អត្ថគាហកៈលើសពី ៣០ (សាមសិប) និងត្រូវប្រើប្រាស់ដើម្បីវិនិយោគតាមការកំណត់របស់ **គ.ម.ក.**។

**មូលនិធិឯកជន** (Private Fund)÷ សំដៅដល់មូលនិធិនៃគម្រោងវិនិយោគរួមដែលប្រមូលផ្តុំពីវិនិយោគិនស្ថាប័ន និង/ឬវិនិយោគិនធនវុឌ្ឍិមិនលើសពី ៣០ (សាមសិប) និងត្រូវប្រើប្រាស់ដើម្បីវិនិយោគតាមការកំណត់របស់ **គ.ម.ក.**។

**អាជីវកម្មក្រោដហ្វាន់ឌីង** (Crowdfunding)÷ សំដៅដល់ប្រតិបត្តិការប្រមូលមូលនិធិតាមរយៈគម្រោងវិនិយោគរួម ឬតាមរយៈអន្តរការីយកម្មរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិរវាងបុគ្គលធ្វើសំណើលក់មូលបត្រ និងវិនិយោគិន។

**អនុក្រឹត្យ**÷ សំដៅដល់អនុក្រឹត្យស្តីពីការអនុវត្តច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន។

**ឯកតាមូលនិធិ** (Fund Unit)÷ សំដៅដល់ចំណែកនៃផលប្រយោជន៍របស់អត្ថគាហកៈក្នុងគម្រោងវិនិយោគរួម។

## ជំពូកទី ២

## បុគ្គលគ្រប់គ្រងមូលនិធិ

### ប្រការ ៥.- បុគ្គលគ្រប់គ្រងមូលនិធិ

បុគ្គលគ្រប់គ្រងមូលនិធិ រួមមានក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងភ្នាក់ងារគ្រប់គ្រងមូលនិធិ ដែលត្រូវទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.មូ.ក.**។

## ផ្នែកទី ១

## ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

### ប្រការ ៦.- អាជ្ញាបណ្ណក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

គ្មានបុគ្គលណាមួយអាចធ្វើជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬតាំងខ្លួនជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិបានទេ លើកលែងតែបុគ្គលនោះទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.មូ.ក.**។

អាជ្ញាបណ្ណរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

អាជ្ញាបណ្ណបន្តរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិមានសុពលភាព ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទអាជ្ញាបណ្ណចាស់អស់សុពលភាព។

### ប្រការ ៧.- អាជីវកម្មរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលទទួលបានអាជ្ញាបណ្ណ អាចធ្វើអាជីវកម្មដូចខាងក្រោម÷

១-បង្កើត គ្រប់គ្រង និងចាត់ចែងមូលនិធិសាធារណៈនៃគម្រោងវិនិយោគរួម។

២-បង្កើត គ្រប់គ្រង និងចាត់ចែងបរធនវិនិយោគអចលនវត្ថុនៃគម្រោងវិនិយោគរួម។

៣-បង្កើត គ្រប់គ្រង និងចាត់ចែងមូលនិធិឯកជននៃគម្រោងវិនិយោគរួម។

៤-បង្កើត គ្រប់គ្រង និងចាត់ចែងមូលនិធិសាធារណៈ និង/ឬឯកជននៃគម្រោងវិនិយោគរួមដែលធ្វើឡើងតាមរយៈប្រព័ន្ធបច្ចេកវិទ្យា ដូចជា តាមទម្រង់ឌីជីថល កម្មវិធីទូរសព្ទ (Mobile App) ឬតាមទម្រង់បច្ចេកវិទ្យាផ្សេងទៀតដែលមានលក្ខណៈប្រហាក់ប្រហែល។

៥-ធ្វើអាជីវកម្មក្រោដហ្វាន់ឌីងក្នុងនាមជាអន្តរការីរវាងបុគ្គលធ្វើសំណើលក់មូលបត្រ និងវិនិយោគិន។

៦-ធ្វើសកម្មភាពអាជីវកម្មផ្សេងទៀតតាមការកំណត់របស់ **គ.មូ.ក.**។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ដែលធ្វើអាជីវកម្មក្នុងចំណុចទី ១, ទី ២, ទី ៣ និងទី ៤ នៃកថាខណ្ឌទី ១ នៃប្រការនេះ អាចផ្តល់យោបល់ និងជួយគម្រោងវិនិយោគរួម ក្នុងការធ្វើសំណើបោះផ្សាយលក់ឯកតាមូលនិធិ រៀបចំផែនការវិនិយោគ គណនាតម្លៃទ្រព្យសកម្មសុទ្ធ កំណត់ថ្លៃឯកតាមូលនិធិ និងថ្លៃទិញត្រឡប់មកវិញ និងកំណត់ការបែងចែកភាគលាភ ប្រាក់ចំណេញមូលធន ឬផលប្រយោជន៍ផ្សេងៗ។

ការបង្កើតគម្រោងវិនិយោគរួមនីមួយៗ ឬធ្វើអាជីវកម្មក្រោដហ្វាន់ឌីង ទោះបីធ្វើឡើងសម្រាប់ក្រុមហ៊ុនផ្ទាល់ ឬក្នុងនាមជាអន្តរការី ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវស្នើសុំការអនុញ្ញាតជាមុនពី **គ.មូ.ក.**។ ប្រព័ន្ធបច្ចេកវិទ្យាដែលប្រើប្រាស់សម្រាប់ការប្រមូលមូលនិធិសាធារណៈ ឬឯកជន ត្រូវមានការទទួលស្គាល់ជាមុនពី **គ.មូ.ក.**។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលធ្វើអាជីវកម្មក្រោមហ្វាន់នីងដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការនេះ ត្រូវពិនិត្យ សិក្សា និងបញ្ជាក់ថាក្រុមហ៊ុនធ្វើសំណើលក់មូលបត្រមួយត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម÷

- ទំហំសរុបនៃសំណើលក់មូលបត្រមិនត្រូវលើសពី ៨០០.០០០.០០០ (ប្រាំបីរយលាន) រៀល គិតចាប់ពីការធ្វើសំណើលក់មូលបត្រដំបូង និង
- ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ គិតចាប់ពីការធ្វើសំណើលក់មូលបត្រនីមួយៗ ទំហំសំណើលក់មូលបត្រមិនត្រូវលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល។

**គ.ម.ក.** អាចធ្វើការកែប្រែការកំណត់ទំហំអតិបរមានៃសំណើលក់មូលបត្ររបស់បុគ្គលធ្វើសំណើលក់មូលបត្រដែលកំណត់ក្នុងកថាខណ្ឌទី ៤ នៃប្រការនេះ ក្នុងរយៈពេល ២ (ពីរ) ឆ្នាំ ម្តង ឬតាមការចាំបាច់។

## ប្រការ ៨.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងបន្តអាជ្ញាបណ្ណក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

បុគ្គលដែលមានបំណងធ្វើអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ឱ្យបានយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទផុតសុពលភាពនៃអាជ្ញាបណ្ណ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំអាជ្ញា-បណ្ណ និងពាក្យស្នើសុំបន្តអាជ្ញាបណ្ណ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់-ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

## ប្រការ ៩.- លក្ខខណ្ឌតម្រូវអាជ្ញាបណ្ណក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ១, ទី ២, ទី ៣ ឬទី ៤ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១- ជាក្រុមហ៊ុនមូលធនដែលចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា។

២- ចុះបញ្ជីពន្ធដារអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៣- មានមូលធនអប្បបរមាទៅតាមប្រភេទអាជីវកម្មនីមួយៗដូចខាងក្រោម÷

ក- ៤.០០០.០០០.០០០ (បួនពាន់លាន) រៀល សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ១ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ។

ខ-២.០០០.០០០.០០០ (ពីរប៊ីលាន) រៀល សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ២ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ។

គ-១.០០០.០០០.០០០ (មួយប៊ីលាន) រៀល សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ៣ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ។

ឃ-៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ៤ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ។

៤-ដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយ នៃមូលធនអប្បបរមាក្នុងគណនីរបស់ **គ.ម.ក.** នៅធនាគារជាតិនៃកម្ពុជា និងត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវមូលធនភាគហ៊ុនិកយ៉ាងតិចស្មើនឹងមូលធនអប្បបរមាដូចមានកំណត់ក្នុងប្រការនេះ។

៥-បំពេញលក្ខខណ្ឌតម្រូវធនធានមនុស្សដូចខាងក្រោម÷

ក-មានយ៉ាងហោចណាស់អភិបាលម្នាក់ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់ ដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ក.** និងបំពេញលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងកថាខណ្ឌទី ១ នៃប្រការ ១០ នៃប្រកាសនេះ។ បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវបំពេញតួនាទី និងភារកិច្ចដូចមានចែងក្នុងប្រការ ១១ នៃប្រកាសនេះ។

ខ-មានភ្នាក់ងារគ្រប់គ្រងមូលនិធិដែលត្រូវទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.**។ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានភ្នាក់ងារគ្រប់គ្រងមូលនិធិដាច់ដោយឡែកពីគ្នា ទៅតាមប្រភេទអាជីវកម្មនីមួយៗ និងត្រូវមានចំនួនភ្នាក់ងារគ្រប់គ្រងមូលនិធិឱ្យសមាមាត្រទៅតាមទំហំអាជីវកម្មរបស់ខ្លួន។

៦-មានអង្គភាពសវនកម្មផ្ទៃក្នុងដូចមានចែងក្នុងប្រការ ១២ នៃប្រកាសនេះ ដែលត្រូវរាយការណ៍អំពីភាពសមស្រប ប្រសិទ្ធភាព ប្រសិទ្ធផលនៃការគ្រប់គ្រងប្រតិបត្តិការ ការគ្រប់គ្រងហានិភ័យ និងការគ្រប់គ្រងផ្ទៃក្នុងនៃក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

៧-មានគណៈកម្មាធិការវិនិយោគដូចមានចែងក្នុងប្រការ ១៣ នៃប្រកាសនេះ ដើម្បីឃ្លាំមើល និងត្រួតពិនិត្យប្រតិបត្តិការ និងការគ្រប់គ្រងគម្រោងវិនិយោគរួម។

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១-ជាក្រុមហ៊ុនមូលធនដែលចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា។

២-ចុះបញ្ជីពន្ធដារអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៣-មានមូលធនអប្បបរមាចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល និងដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយនៃមូលធនអប្បបរមាក្នុងគណនីរបស់ **គ.ម.ក.** នៅធនាគារជាតិនៃកម្ពុជា និងត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវមូលធនភាគហ៊ុនិកយ៉ាងតិចស្មើនឹង

មូលធនអប្បបរមាដូចមានកំណត់ក្នុងប្រការនេះ។

៤- បំពេញលក្ខខណ្ឌតម្រូវធនធានមនុស្សដូចខាងក្រោម៖

ក- មាននាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់ ដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ក.** និងបំពេញលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងកថាខណ្ឌទី ២ នៃប្រការ ១០ នៃប្រកាសនេះ។

ខ- មានភ្នាក់ងារក្រោជហ្វាន់ឌីងដែលត្រូវទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.**។ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានចំនួនភ្នាក់ងារក្រោជហ្វាន់ឌីង ឱ្យសមាមាត្រទៅតាមទំហំអាជីវកម្មរបស់ខ្លួន។

៥- មានគោលការណ៍ស្គាល់អតិថិជន (Know-Your-Client Principle)។

រាល់បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើអាជីវកម្មណាមួយដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១- មានអគារ និងបរិវេណដែលស្ថិតនៅទីតាំងសមស្រប ដើម្បីផ្តល់សេវាកម្មសមស្របដល់អតិថិជននូវសកម្មភាពនានាដែលមានចែងក្នុងអាជ្ញាបណ្ណ ឬមានភស្តុតាងដែលអាចទទួលយកបានដោយអគ្គនាយកនៃ **គ.ម.ក.** ដែលបញ្ជាក់ថាអគារ និងបរិវេណនោះនឹងអាចប្រើប្រាស់បាន ប្រសិនបើអាជ្ញាបណ្ណត្រូវបានផ្តល់ឱ្យ។

២- មានប្រព័ន្ធ ឧបករណ៍ សម្ភារៈជារូបវន្តដូចមានចែងក្នុងប្រការ ១៥ នៃប្រកាសនេះ។

៣- មានផែនការអាជីវកម្មសម្រាប់រយៈពេល ៣ (បី) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៤- មានគោលនយោបាយគ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងសមស្រប។

៥- មិនស្ថិតនៅក្រោមករណីណាមួយដូចខាងក្រោម៖

ក- មិនបានគោរពតាមសេចក្តីណែនាំផ្សេងៗដែលធ្វើឡើងដោយអនុលោមតាមប្រកាសនេះ។

ខ- ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

គ- ស្ថិតក្នុងស្ថានភាពឈានទៅរកការឈប់ធ្វើអាជីវកម្ម ឬការរំលាយអាជីវកម្ម។

ឃ- មិនទូទាត់សងបំណុលតាមសេចក្តីសម្រេចរបស់តុលាការ។

ង- ធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬគ្រឹះស្ថានហិរញ្ញវត្ថុណាមួយដែលធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ដោយសេចក្តីសម្រេចរបស់តុលាការថា ពុំមានការទទួលខុសត្រូវចំពោះការក្ស័យធននេះ។

ច- ធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬគ្រឹះស្ថានហិរញ្ញវត្ថុដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬគ្រឹះស្ថានហិរញ្ញវត្ថុនោះត្រូវបានដកហូតនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ថាពុំមានការទទួលខុសត្រូវចំពោះការដកហូតនេះ។

ឆ- ធ្លាប់ជាបុគ្គលជាប់ពាក់ព័ន្ធនឹងនីតិវិធីដូចជា ការក្ស័យធន ឬការជំរះបញ្ជី នៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

ជ- ស្ថានភាពហិរញ្ញវត្ថុ ឬវិធីសាស្ត្រធ្វើអាជីវកម្មរបស់បុគ្គលដាក់ពាក្យស្នើសុំមិនទាន់មានលក្ខណៈគ្រប់គ្រាន់។

ឈ- មាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬការផ្តល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណដល់បុគ្គលដាក់ពាក្យស្នើសុំអាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

ញ- អភិបាល បុគ្គលិកជាន់ខ្ពស់ ឬភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់របស់បុគ្គលដាក់ពាក្យស្នើសុំ÷

- មិនមានលក្ខណសម្បត្តិ និងអត្តចរិតល្អ
- បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការការពារសាធារណជន
- ធ្លាប់ប្រព្រឹត្តអំពើមិនស្មោះត្រង់ ឬធ្លាប់ប្រព្រឹត្តមិនត្រឹមត្រូវ ឬជាបុគ្គលអសមត្ថភាពក្នុងការផ្តល់សេវាហិរញ្ញវត្ថុ ឬការគ្រប់គ្រងក្រុមហ៊ុន
- បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្តីសម្រេចរបស់ខ្លួន
- បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត កេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ
- ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួន ដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្តីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ
- ស្តែងចេញនូវភាពមិនអាចធ្វើសកម្មភាពក្រោមលក្ខខណ្ឌអាជ្ញាបណ្ណប្រកបដោយប្រសិទ្ធភាព ភាពស្មោះត្រង់ និងយុត្តិធម៌
- ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

ដ-អភិបាល និងបុគ្គលិកជាន់ខ្ពស់ជាប់ពាក់ព័ន្ធនឹងចំណុចណាមួយដូចខាងក្រោម÷

- ជាអភិបាល ឬជាបុគ្គលិកជាន់ខ្ពស់នៃក្រុមហ៊ុនគ្រប់គ្រងមូលនិធិផ្សេងទៀត និងក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស
- ជាសមាជិកនៃគណៈកម្មាធិការវិនិយោគរបស់គម្រោងវិនិយោគរួមដែលគ្រប់គ្រង និងចាត់ចែងដោយក្រុមហ៊ុនគ្រប់គ្រងមូលនិធិផ្សេងទៀត
- ធ្លាប់ធ្វើជាអភិបាលរបស់ក្រុមហ៊ុនដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះត្រូវបានដកហូតដោយអគ្គនាយកនៃ **គ.ម.ក.** ឬដោយស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀត ដែលមានអំណាចប្រហាក់ប្រហែលនឹង **គ.ម.ក.** លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ១០.- បុគ្គលដែលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

ដើម្បីទទួលបានការទទួលស្គាល់គុណវុឌ្ឍិ អភិបាល នាយកប្រតិបត្តិ សមាជិកគណៈកម្មាធិការវិនិយោគ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់ក្នុងក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ១, ទី ២, ទី ៣ ឬទី ៤ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ត្រូវដាក់ពាក្យស្នើសុំមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ព្រមទាំងបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១-មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២-ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-មានសញ្ញាបត្រ និងបទពិសោធន៍ដូចខាងក្រោម÷

ក-អភិបាល និងនាយកប្រតិបត្តិត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងបទពិសោធន៍ការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ។

ខ-សមាជិកគណៈកម្មាធិការវិនិយោគ និងប្រធានប្រតិបត្តិការត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ។

គ-បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកច្បាប់ និងមានបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ។

៤-ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

៥-ចូលរួមវគ្គបណ្តុះបណ្តាលនិងការប្រឡងដែលរៀបចំដោយ **គ.ម.ក.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **គ.ម.ក.** ហើយលទ្ធផលប្រឡងមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ប្រកាសលទ្ធផលប្រឡង។ បុគ្គលដាក់ពាក្យស្នើសុំត្រូវចូលរួមការអប់រំវិជ្ជាជីវៈបន្តដែលរៀបចំដោយ **គ.ម.ក.** ឬដោយស្ថាប័នបណ្តុះបណ្តាលដែលទទួលបានសិទ្ធិពី **គ.ម.ក.** មុនពេលលទ្ធផលប្រឡងអស់សុពលភាព។

៦-មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈដូចមានចែងក្នុងចំណុច ក ដល់ ឌ នៃចំណុចទី ៦ នៃប្រការ ១៩ នៃប្រកាសនេះ។

ដើម្បីទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់ក្នុងក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ត្រូវដាក់ពាក្យស្នើសុំមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ព្រមទាំងបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១-មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២-ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-មានសញ្ញាបត្រ និងបទពិសោធន៍ដូចខាងក្រោម÷

ក-នាយកប្រតិបត្តិ និងប្រធានប្រតិបត្តិការត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យពាក់ព័ន្ធនឹងមូលបត្រ ឬហិរញ្ញវត្ថុ។

ខ-បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកច្បាប់ និងមានបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ។

៤-ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

៥-បំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការនេះ។

៦-មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈដូចមានចែងក្នុងចំណុច ក ដល់ ឌ នៃចំណុចទី ៦ នៃប្រការ ១៩ នៃប្រកាសនេះ។

**ប្រការ ១១.- តួនាទី និងភារកិច្ចរបស់បុគ្គលិកជំនាញផ្នែកច្បាប់**

បុគ្គលិកជំនាញផ្នែកច្បាប់មានតួនាទី និងភារកិច្ចដូចខាងក្រោម÷

១-ផ្តល់ប្រឹក្សា និងត្រួតពិនិត្យឱ្យបានទៀងទាត់នូវអនុលោមភាពតាមច្បាប់ដែលពាក់ព័ន្ធនឹងប្រតិបត្តិការរបស់ក្រុមហ៊ុន និងការអនុវត្តការងាររបស់នាយកប្រតិបត្តិ និងផ្នែកផ្សេងៗ។

២-រក្សាទុក និងត្រួតពិនិត្យឡើងវិញនូវនីតិវិធីអនុលោមភាពតាមច្បាប់សម្រាប់ផ្នែកនីមួយៗរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

៣- ត្រួតពិនិត្យ និង/ឬឃ្លាំមើលភាពមិនប្រក្រតីទាំងឡាយដែលកើតមាននៅក្នុងប្រតិបត្តិការរបស់ក្រុមហ៊ុន។ រាល់លទ្ធផលដែលបានរកឃើញត្រូវរក្សាទុកជាឯកសារឲ្យបានត្រឹមត្រូវ។ ក្នុងករណីចាំបាច់ បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវជូនដំណឹង និង/ឬប្រឹក្សាជាមួយក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និង/ឬ **គ.ម.ក.**។

៤- ទទួលបន្ទុករៀបចំសៀវភៅមគ្គុទ្ទេសក៍អនុលោមភាពតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈសម្រាប់និយោជិតរបស់ក្រុមហ៊ុន។ បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវសហការជាមួយផ្នែកពាក់ព័ន្ធក្នុងការត្រួតពិនិត្យឡើងវិញ និងធ្វើបច្ចុប្បន្នកម្មសៀវភៅមគ្គុទ្ទេសក៍អនុលោមភាពតាមច្បាប់ និងក្រមសីលធម៌វិជ្ជាជីវៈ។

៥- ផ្តល់ការបណ្តុះបណ្តាល ធ្វើបច្ចុប្បន្នកម្ម និង/ឬផ្តល់ប្រឹក្សាដល់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និង/ឬសមាជិកនៃក្រុមប្រឹក្សាភិបាល អំពីបញ្ហាអនុលោមភាពតាមច្បាប់ស្តីពីការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម និងការអភិវឌ្ឍបទប្បញ្ញត្តិ។

៦- ត្រួតពិនិត្យ និងដោះស្រាយទំនាស់ផលប្រយោជន៍ផ្សេងៗ។

៧- រាយការណ៍ទៅក្រុមប្រឹក្សាភិបាល និងគណៈកម្មាធិការពាក់ព័ន្ធផ្សេងទៀតអំពីភាពសមស្របនៃការជួញដូរទ្រព្យសម្បត្តិបរធនវិនិយោគរបស់គម្រោងវិនិយោគរួម។

៨- ផ្តល់ប្រឹក្សាលើបញ្ហាអនុលោមតាមបទប្បញ្ញត្តិពាក់ព័ន្ធនឹងការគ្រប់គ្រងមូលនិធិ និងការជួញដូរដែលធ្វើឡើងដោយនិយោជិត បុគ្គលិកជាន់ខ្ពស់ អភិបាលរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងសមាជិកគណៈកម្មាធិការវិនិយោគ។

៩- តួនាទី និងភារកិច្ចផ្សេងទៀតដែលអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

## ប្រការ ១២.- អង្គភាពសវនកម្មផ្ទៃក្នុង

អង្គភាពសវនកម្មផ្ទៃក្នុងត្រូវ÷

១- គោរពតាមលក្ខខណ្ឌនៃក្របខ័ណ្ឌសវនកម្មផ្ទៃក្នុងដែលត្រូវបានកំណត់ច្បាស់លាស់អំពីវិសាលភាព គោលដៅ វិធីសាស្ត្រ និងលក្ខខណ្ឌតម្រូវនៃការរាយការណ៍។

២- រៀបចំផែនការត្រួតពិនិត្យ និងកត់ត្រាឲ្យបានសមស្របគ្រប់សកម្មភាពការងារសវនកម្មដែលបានធ្វើ និងកត់ត្រាលទ្ធផល សេចក្តីសន្និដ្ឋាន និងអនុសាសន៍។

៣- រៀបចំរបាយការណ៍សវនកម្មដោយត្រូវរំលេចបញ្ហាដែលត្រូវដោះស្រាយឲ្យបានសមស្រប និងទាន់ពេលវេលា។

## ប្រការ ១៣.- គណៈកម្មាធិការវិនិយោគ

គណៈកម្មាធិការវិនិយោគត្រូវមានសមាជិករូបវន្តបុគ្គលយ៉ាងតិច ៣ (បី) រូប ដែលក្នុងនោះសមាជិកនីមួយៗត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ក.** និងបំពេញលក្ខខណ្ឌតម្រូវដូចមាន

ចែងនៅក្នុងកថាខណ្ឌទី ១ នៃប្រការ ១០ នៃប្រកាសនេះ។

សមាជិកគណៈកម្មាធិការវិនិយោគមិនត្រូវជា÷

១- សមាជិកគណៈកម្មាធិការវិនិយោគនៃក្រុមហ៊ុនគ្រប់គ្រងមូលនិធិផ្សេងទៀត។

២- អភិបាល នាយកប្រតិបត្តិ ឬបុគ្គលិកជាន់ខ្ពស់នៃក្រុមហ៊ុនគ្រប់គ្រងមូលនិធិផ្សេងទៀត។

៣- អភិបាល នាយកប្រតិបត្តិ ឬបុគ្គលិកជាន់ខ្ពស់នៃក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស។

គណៈកម្មាធិការវិនិយោគត្រូវធានាថា គម្រោងវិនិយោគរួមត្រូវបានគ្រប់គ្រងដោយអនុលោមតាមគោលដៅវិនិយោគរបស់គម្រោងវិនិយោគរួម កិច្ចព្រមព្រៀងបរធនបាលកិច្ច ឯកសារផ្តល់ព័ត៌មាន គោលនយោបាយ និងការដាក់កំហិតទៅលើការវិនិយោគផ្ទៃក្នុង ច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំពាក់ព័ន្ធជាធរមាន។

គណៈកម្មាធិការវិនិយោគមានតួនាទី និងភារកិច្ចដូចខាងក្រោម÷

១- ជ្រើសរើសយុទ្ធសាស្ត្រសមស្របដើម្បីសម្រេចបាននូវលទ្ធផលនៃការវិនិយោគអនុលោមតាមគោលនយោបាយគ្រប់គ្រងគម្រោងវិនិយោគរួម។

២- ធានាថាយុទ្ធសាស្ត្រដែលបានជ្រើសរើសត្រូវបានអនុវត្តត្រឹមត្រូវ និងមានប្រសិទ្ធភាពដោយក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

៣- ឃ្លាំមើល ត្រួតពិនិត្យ វាស់វែង និងវាយតម្លៃយ៉ាងសកម្មនូវលទ្ធផលនៃការអនុវត្តការគ្រប់គ្រងគម្រោងវិនិយោគរួមរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

## ប្រការ ១៤.- ការតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល សមាសភាពគណៈកម្មាធិការវិនិយោគ និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល អភិបាលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ សមាសភាពគណៈកម្មាធិការវិនិយោគ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់។ ប្រសិនបើតំណែងសម្រាប់អភិបាលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់នៅទំនេរ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

ប្រសិនបើសមាជិកគណៈកម្មាធិការវិនិយោគមានចំនួនតិចជាង ៣ (បី) រូប ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ១៥.- ប្រព័ន្ធ ឧបករណ៍ និងសម្ភារៈរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

បុគ្គលដាក់ពាក្យស្នើសុំត្រូវមានប្រព័ន្ធ ឧបករណ៍ និងសម្ភារៈដូចខាងក្រោម÷

១- រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ធ្វើអាជីវកម្មដែលសុំអាជ្ញាបណ្ណ ឱ្យមានលក្ខណៈស្ថិរភាព និងសុវត្ថិភាព។

២- មានប្រព័ន្ធព័ត៌មានវិទ្យាដែលមានសមត្ថភាពគ្រប់គ្រាន់សម្រាប់ប្រតិបត្តិការទិញ-លក់ឯកតាមូលនិធិ និង/ឬមូលបត្រដែលរំពឹងទុកនាពេលអនាគត និងត្រូវធ្វើតេស្តសាកល្បងប្រព័ន្ធនោះឱ្យបានត្រឹមត្រូវ។

៣- រៀបចំវិធានការសុវត្ថិភាពដើម្បីទប់ស្កាត់សាធារណជនពីខាងក្រៅដែលមិនមានការអនុញ្ញាតឱ្យចូលក្នុងកន្លែងហាមឃាត់។

៤- ដំឡើងឱ្យបានពេញលេញនូវប្រព័ន្ធទ្រទ្រង់ (Backup System) និងប្រព័ន្ធដែលអាចការពារភាពលើសហួសសមត្ថភាព (Exceeded Capacity) ឬការខូចខាត (System Failure) និងដែលអាចដោះស្រាយរាល់បញ្ហាដែលអាចកើតមាន។

បុគ្គលដាក់ពាក្យស្នើសុំត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ **គ.ម.ក.** ក្នុងការបំពេញភារកិច្ចត្រួតពិនិត្យលើប្រព័ន្ធ ឧបករណ៍ និងសម្ភារៈចម្បងរបស់ក្រុមហ៊ុន។

### ប្រការ ១៦.- ការលុបចោលអាជ្ញាបណ្ណរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

អគ្គនាយកនៃ **គ.ម.ក.** អាចលុបចោលអាជ្ញាបណ្ណក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្នុងករណីក្រុមហ៊ុនគ្រប់-គ្រងមូលនិធិស្នើសុំផ្អាក ឬឈប់ធ្វើប្រតិបត្តិការអាជីវកម្ម។

## ផ្នែកទី ២
## ភ្នាក់ងារគ្រប់គ្រងមូលនិធិ

### ប្រការ ១៧.- អាជ្ញាបណ្ណភ្នាក់ងារគ្រប់គ្រងមូលនិធិ

គ្មានបុគ្គលណាមួយអាចធ្វើជាភ្នាក់ងារគ្រប់គ្រងមូលនិធិ ឬតាំងខ្លួនជាភ្នាក់ងារគ្រប់គ្រងមូលនិធិបានទេ លើកលែងតែបុគ្គលនោះទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.**។

អាជ្ញាបណ្ណរបស់ភ្នាក់ងារគ្រប់គ្រងមូលនិធិមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

អាជ្ញាបណ្ណបន្តរបស់ភ្នាក់ងារគ្រប់គ្រងមូលនិធិមានសុពលភាព ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទអាជ្ញាបណ្ណចាស់អស់សុពលភាព។

### ប្រការ ១៨.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងបន្តអាជ្ញាបណ្ណភ្នាក់ងារគ្រប់គ្រងមូលនិធិ

បុគ្គលដែលមានបំណងធ្វើជាភ្នាក់ងារគ្រប់គ្រងមូលនិធិ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ ភ្នាក់ងារគ្រប់គ្រងមូលនិធិត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមក **គ.ម.ក.** ទៅតាមទម្រង់ និងឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ឱ្យបានយ៉ាងតិច ៣០ (សាមសិប)

ថ្ងៃ មុនកាលបរិច្ឆេទអាជ្ញាបណ្ណចាស់អស់សុពលភាព។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់-ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ ១៩.- លក្ខខណ្ឌតម្រូវអាជ្ញាបណ្ណភ្នាក់ងារគ្រប់គ្រងមូលនិធិ**

ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាភ្នាក់ងារគ្រប់គ្រងមូលនិធិ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១- មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២- ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣- បំពេញលក្ខខណ្ឌយ៉ាងហោចណាស់មួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម÷

ក- បានប្រឡងជាប់កម្រិតទី ១ ជាអ្នកវិភាគហិរញ្ញវត្ថុជំនាញ (Chartered Financial Analyst) និងមានបទពិសោធន៍ការងារយ៉ាងតិចរយៈពេល ៣ (បី) ឆ្នាំ ក្នុងវិស័យមូលបត្រ ហិរញ្ញវត្ថុ ឬវិស័យពាក់ព័ន្ធនឹងគម្រោងវិនិយោគរួមដែលត្រូវគ្រប់គ្រង។

ខ- មានសញ្ញាបត្រយ៉ាងតិចកម្រិតបរិញ្ញាបត្រជាន់ខ្ពស់ពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងមានបទពិសោធន៍ការងារយ៉ាងតិចរយៈពេល ៣ (បី) ឆ្នាំ ក្នុងវិស័យមូលបត្រ ហិរញ្ញវត្ថុ ឬវិស័យពាក់ព័ន្ធនឹងគម្រោងវិនិយោគរួមដែលត្រូវគ្រប់គ្រង។

គ- ជាអ្នកវិភាគហិរញ្ញវត្ថុជំនាញ ឬគណនេយ្យករជំនាញ (Certified Public Accountant) និងមានបទពិសោធន៍ការងារយ៉ាងតិចរយៈពេល ១ (មួយ) ឆ្នាំ ក្នុងវិស័យមូលបត្រ ហិរញ្ញវត្ថុ ឬវិស័យពាក់ព័ន្ធនឹងគម្រោងវិនិយោគរួមដែលត្រូវគ្រប់គ្រង។

ឃ- ធ្លាប់ទទួលបានអាជ្ញាបណ្ណធ្វើជាភ្នាក់ងារគ្រប់គ្រងមូលនិធិក្នុងរយៈពេលយ៉ាងតិច ៣ (បី) ឆ្នាំ ពីយុត្តាធិការដែលទទួលស្គាល់ដោយ **គ.ម.ក.**។

៤- ផ្តល់លិខិតយល់ព្រមឱ្យធ្វើជាភ្នាក់ងារគ្រប់គ្រងមូលនិធិពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

៥- បំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ១០ នៃប្រកាសនេះ។

៦- មិនស្ថិតនៅក្រោមករណីណាមួយដូចខាងក្រោម÷

ក- មិនបានគោរពតាមសេចក្តីណែនាំផ្សេងៗដែលធ្វើឡើងដោយអនុលោមតាមប្រកាសនេះ។

ខ- ព័ត៌មាន ឬឯកសារដែលបុគ្គលដាក់ពាក្យស្នើសុំបានដាក់ជូន **គ.ម.ក.** មានលក្ខណៈក្លែងបន្លំ ឬនាំឱ្យយល់ខុស។

គ- មិនទូទាត់សងបំណុលតាមសេចក្តីសម្រេចរបស់តុលាការ។

ឃ- ធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬគ្រឹះស្ថានហិរញ្ញវត្ថុណាមួយដែលធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ចុងក្រោយគិតត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ដោយសេចក្ដីសម្រេចរបស់តុលាការថា ពុំមានការទទួលខុសត្រូវចំពោះការក្ស័យធននេះ។

ង- ធ្លាប់ធ្វើជាភាគហ៊ុនិកដែលកាន់កាប់ភាគហ៊ុនមានសិទ្ធិបោះឆ្នោតចំនួនច្រើនលើសលប់ ឬបុគ្គលដែលមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬគ្រឹះស្ថានហិរញ្ញវត្ថុដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬគ្រឹះស្ថានហិរញ្ញវត្ថុនោះត្រូវបានដកហូតនៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំ ចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ លើកលែងតែបុគ្គលដែលត្រូវបានទទួលស្គាល់ថា ពុំមានការទទួលខុសត្រូវចំពោះការដកហូតនេះ។

ច- បានប្រព្រឹត្តល្មើសនឹងច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធនឹងការការពារសាធារណជន។

ឆ- ធ្លាប់ប្រព្រឹត្តអំពើមិនស្មោះត្រង់ ឬធ្លាប់ប្រព្រឹត្តមិនត្រឹមត្រូវ ឬជាបុគ្គលអសមត្ថភាពក្នុងការផ្ដល់សេវាហិរញ្ញវត្ថុ ឬការគ្រប់គ្រងក្រុមហ៊ុន។

ជ- បានធ្វើ ឬជាប់ពាក់ព័ន្ធនឹងអាជីវកម្មណាមួយផ្សេងទៀតដែលធ្វើឱ្យមានការសង្ស័យចំពោះសមត្ថភាព និងសុក្រឹតភាពនៃសេចក្ដីសម្រេចរបស់ខ្លួន។

ឈ- បានធ្វើអាជីវកម្មដែលមានលក្ខណៈបោកបញ្ឆោត ឬកេងប្រវ័ញ្ច ឬមិនត្រឹមត្រូវដោយប្រការណាមួយ។

ញ- ស្ដែងចេញនូវភាពមិនអាចធ្វើសកម្មភាពដើម្បីផលប្រយោជន៍អតិថិជនរបស់ខ្លួនដោយសារតែកេរ្តិ៍ឈ្មោះ បុគ្គលិកលក្ខណៈ សេចក្ដីសុចរិតផ្នែកហិរញ្ញវត្ថុ និងភាពដែលអាចទុកចិត្តបានរបស់បុគ្គលទាំងនោះ។

ដ- ធ្លាប់ត្រូវបានប្រកាសក្ស័យធននៅក្នុង ឬក្រៅព្រះរាជាណាចក្រកម្ពុជាក្នុងរយៈពេល ៥ (ប្រាំ) ឆ្នាំចុងក្រោយគិតមកត្រឹមកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

ឋ- ជាសមាជិកគណៈកម្មាធិការវិនិយោគរបស់គម្រោងវិនិយោគរួមដែលគ្រប់គ្រង និងចាត់ចែងដោយក្រុមហ៊ុនគ្រប់គ្រងមូលនិធិផ្សេងទៀត។

ឌ- ធ្លាប់បានទទួលអាជ្ញាបណ្ណពី **គ.ម.ក.** ដែលអាជ្ញាបណ្ណនោះត្រូវបានដកហូត ឬព្យួរទុក ឬធ្លាប់ប្រព្រឹត្តអំពើល្មើសដែលមានចែងក្នុងច្បាប់។

ឍ- ស្ដែងចេញនូវភាពមិនអាចធ្វើសកម្មភាពក្រោមលក្ខខណ្ឌអាជ្ញាបណ្ណប្រកបដោយប្រសិទ្ធភាពភាពស្មោះត្រង់ និងយុត្តិធម៌។

ណ-មាន ឬអាចនឹងមានការពាក់ព័ន្ធនឹងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម ឬការផ្ដល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណដល់បុគ្គលដាក់ពាក្យស្នើសុំ អាចនឹងនាំឱ្យប៉ះពាល់ផលប្រយោជន៍សាធារណៈ។

ត-ជាអភិបាល ជានិយោជិត ឬជាភ្នាក់ងារគ្រប់គ្រងមូលនិធិនៃក្រុមហ៊ុនគ្រប់គ្រងមូលនិធិផ្សេងទៀត ឬក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស។

## ប្រការ ២០.- ការលុបចោលអាជ្ញាបណ្ណរបស់ភ្នាក់ងារគ្រប់គ្រងមូលនិធិ

អគ្គនាយកនៃ **គ.ម.ក.** អាចលុបចោលអាជ្ញាបណ្ណភ្នាក់ងារគ្រប់គ្រងមូលនិធិ ក្នុងករណីភ្នាក់ងារគ្រប់គ្រងមូលនិធិ ស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១-ក្លាយជាអសមត្ថជន។

២-លាឈប់ ឬផ្លាស់ប្ដូរការងារ។

៥-ហេតុការណ៍ណាមួយដែលភ្នាក់ងារគ្រប់គ្រងមូលនិធិមិនអាចអនុវត្តការងារបាន។

# ផ្នែកទី ៣
# ភ្នាក់ងារក្រោជហ្វាន់ឌីង

## ប្រការ ២១.- អាជ្ញាបណ្ណភ្នាក់ងារក្រោជហ្វាន់ឌីង

គ្មានបុគ្គលណាមួយអាចធ្វើជាភ្នាក់ងារក្រោជហ្វាន់ឌីង ឬតាំងខ្លួនជាភ្នាក់ងារក្រោជហ្វាន់ឌីងបានទេ លើកលែងតែបុគ្គលនោះទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.**។

អាជ្ញាបណ្ណរបស់ភ្នាក់ងារក្រោជហ្វាន់ឌីងមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

អាជ្ញាបណ្ណបន្តរបស់ភ្នាក់ងារក្រោជហ្វាន់ឌីងមានសុពលភាព ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទអាជ្ញាបណ្ណចាស់អស់សុពលភាព។

## ប្រការ ២២.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ និងបន្តអាជ្ញាបណ្ណភ្នាក់ងារក្រោជហ្វាន់ឌីង

បុគ្គលដែលមានបំណងធ្វើជាភ្នាក់ងារក្រោជហ្វាន់ឌីង ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្ដល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ ភ្នាក់ងារក្រោជហ្វាន់ឌីងត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្ដល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃមុនកាលបរិច្ឆេទអាជ្ញាបណ្ណចាស់អស់សុពលភាព។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬបដិសេធផ្ដល់អាជ្ញាបណ្ណ/បន្តអាជ្ញាបណ្ណដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការនេះ

ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃគិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

**ប្រការ ២៣.- លក្ខខណ្ឌតម្រូវអាជ្ញាបណ្ណភ្នាក់ងារក្រោដហ្វាន់ឌីង**

ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាភ្នាក់ងារក្រោដហ្វាន់ឌីង បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១- មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២- ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣- បំពេញលក្ខខណ្ឌយ៉ាងហោចណាស់មួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម÷

ក- មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យហិរញ្ញវត្ថុ មូលបត្រ សេដ្ឋកិច្ច ច្បាប់ គណនេយ្យ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែល។

ខ- មានបទពិសោធន៍ការងារយ៉ាងតិច ១ (មួយ) ឆ្នាំ ក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ។

៤- ផ្តល់លិខិតយល់ព្រមឱ្យធ្វើជាភ្នាក់ងារក្រោដហ្វាន់ឌីងពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

៥- បំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ១០ នៃប្រកាសនេះ។

៦- មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈដូចមានចែងក្នុងចំណុចទី ៦ នៃប្រការ ១៩ នៃប្រកាសនេះ។

៧- មិនស្ថិតនៅក្រោមករណីណាមួយដូចខាងក្រោម÷

ក- ជាភ្នាក់ងារគ្រប់គ្រងមូលនិធិ។

ខ- ជានិយោជិតនៃក្រុមហ៊ុនគ្រប់គ្រងមូលនិធិផ្សេងទៀត ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ក្រុមហ៊ុនសមភាគីកណ្តាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ និងអ្នកចូលរួមដទៃទៀតក្នុងទីផ្សារមូលបត្រ។

**ប្រការ ២៤.- ការលុបចោលអាជ្ញាបណ្ណរបស់ភ្នាក់ងារក្រោដហ្វាន់ឌីង**

អគ្គនាយកនៃ **គ.ម.ក.** អាចលុបចោលអាជ្ញាបណ្ណរបស់ភ្នាក់ងារក្រោដហ្វាន់ឌីង ក្នុងករណីភ្នាក់ងារក្រោដហ្វាន់ឌីង ស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១- ក្លាយជាអសមត្ថជន។

២- លាឈប់ ឬផ្លាស់ប្តូរការងារ។

៣- ព្យួរការងារ ឬហេតុការណ៍ណាមួយដែលភ្នាក់ងារក្រោដហ្វាន់ឌីងមិនអាចអនុវត្តការងារបាន។

## ជំពូកទី ៣

## ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស

**ប្រការ ២៥.- អាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស**

គ្មានបុគ្គលណាមួយអាចធ្វើជាក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ឬតាំងខ្លួនជាក្រុមហ៊ុនថែរក្សាទ្រព្យ

សម្បត្តិជំនួសបានទេ លើកលែងតែបុគ្គលនោះទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.**។

អាជ្ញាបណ្ណរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាល-បរិច្ឆេទចេញអាជ្ញាបណ្ណ។

អាជ្ញាបណ្ណបន្តរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសមានសុពលភាព ៣ (បី) ឆ្នាំ គិតចាប់ពីកាល-បរិច្ឆេទអាជ្ញាបណ្ណចាស់អស់សុពលភាព។

## ប្រការ ២៦.- អាជីវកម្មរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសដែលទទួលបានអាជ្ញាបណ្ណអាចធ្វើអាជីវកម្មដូចខាងក្រោម÷

១- គ្រប់គ្រង និងថែរក្សាសុវត្ថិភាពសាច់ប្រាក់ ឬទ្រព្យសម្បត្តិរបស់បុគ្គលមួយ ឬបុគ្គលមួយក្រុម ឬទ្រព្យសម្បត្តិបរធនវិនិយោគ។

២- ទទួល និងចាត់ចែងទ្រព្យសម្បត្តិបរធនវិនិយោគដោយអនុលោមតាមកិច្ចព្រមព្រៀងបរធនបាលកិច្ច សេចក្ដីណែនាំពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនវិនិយោគរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និង/ ឬបទប្បញ្ញត្តិពាក់ព័ន្ធ។

៣- ធ្វើជាតំណាងនៃភាពជាម្ចាស់កម្មសិទ្ធិស្របច្បាប់លើទ្រព្យសម្បត្តិបរធនវិនិយោគ។

៤- ទូទាត់ថ្លៃសម្រាប់ការទិញឯកតាមូលនិធិត្រឡប់មកវិញ ទូទាត់ប្រាក់ចំណេញ ភាគលាភ ការប្រាក់ ឬលាភការផ្សេងៗដោយអនុលោមតាមកិច្ចព្រមព្រៀងបរធនបាលកិច្ច សេចក្ដីណែនាំពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនវិនិយោគរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និង/ ឬបទប្បញ្ញត្តិពាក់ព័ន្ធ។

៥- ត្រួតពិនិត្យសេចក្ដីណែនាំផ្សេងៗពាក់ព័ន្ធនឹងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនវិនិយោគ និងការសម្រេចចិត្តវិនិយោគរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ព្រមទាំងធានាថាការវិនិយោគ និងកម្ចីផ្សេងៗដែលត្រូវបានអនុញ្ញាតដល់គម្រោងវិនិយោគរួម ត្រូវបានអនុវត្តត្រឹមត្រូវ។

៦- ត្រួតពិនិត្យ និងតាមដានយ៉ាងសកម្ម ព្រមទាំងធានាថាប្រតិបត្តិការ និងការគ្រប់គ្រងគម្រោងវិនិ-យោគរួមរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ រួមទាំងការគណនាតម្លៃទ្រព្យសកម្មសុទ្ធ ថ្លៃឯកតាមូលនិធិ ថ្លៃទិញឯកតាមូលនិធិត្រឡប់មកវិញ និងចំណូលទទួលបាន ធ្វើឡើងដោយអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៧- ធ្វើសកម្មភាពអាជីវកម្មផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ២៧.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស

បុគ្គលដែលមានបំណងធ្វើអាជីវកម្មជាក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ត្រូវដាក់ពាក្យស្នើសុំអាជ្ញា-បណ្ណមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្ដល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្ដល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ឱ្យបានយ៉ាងតិច ៦០

(ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទអាជ្ញាបណ្ណចាស់អស់សុពលភាព។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំអាជ្ញាបណ្ណ និងពាក្យស្នើសុំបន្តអាជ្ញាបណ្ណ។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការនេះក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

## ប្រការ ២៨.- លក្ខខណ្ឌតម្រូវអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១-ជាក្រុមហ៊ុនមូលធនដែលចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា។

២-ចុះបញ្ជីពន្ធដារអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៣-មានមូលធនអប្បបរមាចំនួន ៤.០០០.០០០.០០០ (បួនបីលាន) រៀល និងដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយ នៃមូលធនអប្បបរមាក្នុងគណនីរបស់ **គ.ម.ក.** នៅធនាគារជាតិនៃកម្ពុជា។ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវមូលធនភាគហ៊ុនិកយ៉ាងតិចស្មើនឹងមូលធនអប្បបរមាដូចមានចែងក្នុងប្រការនេះ។ បុគ្គលដាក់ពាក្យស្នើសុំដែលជាធនាគារពាណិជ្ជនៅក្នុងព្រះរាជាណាចក្រកម្ពុជា មិនតម្រូវឱ្យបំពេញលក្ខខណ្ឌមូលធនអប្បបរមានេះទេ ប៉ុន្តែត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ៦០០.០០០.០០០ (ប្រាំមួយរយលាន) រៀល ក្នុងគណនីរបស់ **គ.ម.ក.** នៅធនាគារជាតិនៃកម្ពុជា។

៤-មានយ៉ាងហោចណាស់អភិបាលម្នាក់ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករជំនាញមូលនិធិ ដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ក.** និងបំពេញលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងប្រការ ២៩ នៃប្រកាសនេះ។

៥-ត្រូវមានអគារ និងបរិវេណដែលស្ថិតនៅទីតាំងសមស្រប និងដាច់ដោយឡែកពីអាជីវកម្មផ្សេងទៀត។

៦-មានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់ ឧបករណ៍ សម្ភារៈជារូបវន្ត ដើម្បីផ្តល់សេវាជាក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស និងត្រូវដំឡើងឱ្យបានពេញលេញនូវប្រព័ន្ធទ្រទ្រង់ និងប្រព័ន្ធដែលអាចការពារភាពលើសហួសសមត្ថភាព ឬការខូចខាត និងដែលអាចដោះស្រាយរាល់បញ្ហាដែលអាចកើតមាន។

៧-មានវិធានប្រតិបត្តិការដូចមានចែងក្នុងប្រការ ៣០ នៃប្រកាសនេះ។

៨-រៀបចំផែនការអាជីវកម្មសម្រាប់រយៈពេល ៣ (បី) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៩-មានគោលនយោបាយសម្រាប់គ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងសមស្រប។

១០-មានអភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមិនជាប់ពាក់ព័ន្ធនឹងចំណុចណាមួយដូចខាងក្រោម÷

- ជាអភិបាល ឬជាបុគ្គលិកជាន់ខ្ពស់នៃក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសផ្សេងទៀត ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង
- ធ្លាប់ធ្វើជាអភិបាលរបស់ក្រុមហ៊ុនដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះត្រូវបានដកហូត ដោយអគ្គនាយកនៃ **គ.ម.ក.** ឬដោយស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀតដែលមានអំណាចប្រហាក់ប្រហែលនឹង **គ.ម.ក.** លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

១១-មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈដូចមានចែងក្នុងចំណុច ក ដល់ ញ នៃចំណុចទី ៥ នៃកថាខណ្ឌទី ៣ នៃប្រការ ៩ នៃប្រកាសនេះ។

## ប្រការ ២៩.- បុគ្គលដែលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស

ដើម្បីទទួលបានការទទួលស្គាល់គុណវុឌ្ឍិ អភិបាល នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករជំនាញមូលនិធិ ត្រូវដាក់ពាក្យស្នើសុំមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ព្រមទាំងបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១-មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២-ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-មានសញ្ញាបត្រ និងបទពិសោធន៍ការងារដូចខាងក្រោម÷

ក-អភិបាល និងនាយកប្រតិបត្តិ ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងមានបទពិសោធន៍ការងារយ៉ាងតិច ៥ (ប្រាំ) ឆ្នាំ ក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ។

ខ-ប្រធានប្រតិបត្តិការ ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ។

គ-បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកច្បាប់ និងមានបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ។

ឃ-គណនេយ្យករជំនាញមូលនិធិត្រូវបំពេញលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម÷

- មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកគណនេយ្យ ឬផ្នែកពាក់ព័ន្ធ និងមានបទពិសោធន៍ការងារធ្វើជាគណនេយ្យករយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ
- ជាគណនេយ្យករជំនាញ។

៤-ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស។
៥-បំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ១០ នៃប្រកាសនេះ។
៦-មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈដូចមានចែងក្នុងចំណុច ក ដល់ ឌ នៃចំណុចទី ៦ នៃប្រការ ១៩ នៃប្រកាសនេះ។

## ប្រការ ៣០.- វិធានប្រតិបត្តិការ

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវមានវិធានប្រតិបត្តិការសមស្របដើម្បី÷
១-គ្រប់គ្រង និងថែរក្សាសុវត្ថិភាពសាច់ប្រាក់ ឬទ្រព្យសម្បត្តិ។
២-គ្រប់គ្រងទ្រព្យសម្បត្តិបរធនវិនិយោគអនុលោមតាមកិច្ចព្រមព្រៀងបរធនបាលកិច្ច គោលការណ៍ណែនាំ និងបទប្បញ្ញត្តិពាក់ព័ន្ធ។
៣-ធានានូវភាពដាច់ដោយឡែកពីគ្នារវាងទ្រព្យសម្បត្តិបរធនវិនិយោគ និងទ្រព្យសម្បត្តិផ្ទាល់របស់ក្រុមហ៊ុន។
៤-កត់ត្រាភាពជាម្ចាស់កម្មសិទ្ធិ ឬសិទ្ធិដែលមានលើទ្រព្យសម្បត្តិបរធនវិនិយោគ ចំណូលចំណាយ និងរាល់បំណុលដែលពាក់ព័ន្ធនឹងការថែរក្សាទ្រព្យសម្បត្តិជំនួស សម្រាប់គម្រោងវិនិយោគរួមនីមួយៗ។
៥-ត្រួតពិនិត្យផលប្រយោជន៍ផ្សេងៗដែលទទួលបានពីទ្រព្យសម្បត្តិបរធនវិនិយោគ។
៦-បែងចែកផលប្រយោជន៍ផ្សេងៗដល់អត្ថគាហកៈ។
៧-ត្រួតពិនិត្យ និងទប់ស្កាត់ការគ្រប់គ្រងទ្រព្យសម្បត្តិបរធនវិនិយោគដែលផ្ទុយពីបញ្ញត្តិក្នុងកិច្ចព្រមព្រៀងបរធនបាលកិច្ច គោលការណ៍ណែនាំ និងបទប្បញ្ញត្តិពាក់ព័ន្ធ និងការគ្រប់គ្រងទ្រព្យសម្បត្តិបរធនវិនិយោគដែលមានភាពមិនស្មោះត្រង់។

## ប្រការ ៣១.- ការតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល អភិបាលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករជំនាញមូលនិធិ។ ប្រសិនបើតំណែងសម្រាប់អភិបាលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករជំនាញមូលនិធិ នៅទំនេរ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៣២.- ការលុបចោលអាជ្ញាបណ្ណរបស់ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស

អគ្គនាយកនៃ **គ.ម.ក.** អាចលុបចោលអាជ្ញាបណ្ណក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្នុងករណីក្រុម-

ហ៊ុនថែរក្សាទ្រព្យសម្បត្តិជិនួសស្នើសុំផ្អាក ឬឈប់ធ្វើប្រតិបត្តិការអាជីវកម្ម។

## ជំពូកទី ៤
## ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

### ប្រការ ៣៣.- អាជ្ញាបណ្ណ/ការអនុញ្ញាតក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

គ្មានបុគ្គលណាមួយអាចធ្វើជាក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ឬតាំងខ្លួនជាក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង បានទេ លើកលែងតែបុគ្គលនោះទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

អាជ្ញាបណ្ណ/ការអនុញ្ញាតរបស់ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង មានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ/ការអនុញ្ញាត។

អាជ្ញាបណ្ណ/ការអនុញ្ញាតបន្តរបស់ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង មានសុពលភាព ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនមូលបត្រ និងក្រុមហ៊ុនសមភាគីកណ្ដាលដែលទទួលបានអាជ្ញាបណ្ណពី **គ.ម.ក.** អាចដាក់ពាក្យស្នើសុំការអនុញ្ញាតបន្ថែមមក **គ.ម.ក.** ដើម្បីធ្វើអាជីវកម្មចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សងឯកតាមូលនិធិនៃគម្រោងវិនិយោគរួម ដោយអនុលោមតាមប្រកាសនេះ។

### ប្រការ ៣៤.- អាជីវកម្មរបស់ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត អាចធ្វើអាជីវកម្មចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ដូចខាងក្រោម÷

១-ចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សងឯកតាមូលនិធិក្នុងគម្រោងវិនិយោគរួម។

២-ផ្ដល់ប្រឹក្សាអំពីការវិនិយោគលើឯកតាមូលនិធិដល់អតិថិជន។

### ប្រការ ៣៥.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត និងបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

បុគ្គលដែលមានបំណងធ្វើអាជីវកម្មចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្ដល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្ដល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ឱ្យបានយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត និងពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៦០(ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

## ប្រការ ៣៦.- លក្ខខណ្ឌតម្រូវអាជ្ញាបណ្ណ/ការអនុញ្ញាតក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើអាជីវកម្មចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម÷

១-ជាក្រុមហ៊ុនដែលចុះបញ្ជីពាណិជ្ជកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

២-ចុះបញ្ជីពន្ធដារអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៣-មានមូលធនអប្បបរមាចំនួន ១.០០០.០០០.០០០ (មួយប៊ីលាន) រៀល និងត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយនៃមូលធនអប្បបរមាក្នុងគណនីរបស់ **គ.ម.ក.** នៅធនាគារជាតិនៃកម្ពុជា។ លក្ខខណ្ឌមូលធនអប្បបរមាមិនអនុវត្តចំពោះបុគ្គលដាក់ពាក្យស្នើសុំដែលជាធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនសមភាគីកណ្តាល និងក្រុមហ៊ុនគ្រប់គ្រងមូលនិធិដែលមានដើមទុនអប្បបរមា ២.០០០.០០០.០០០ (ពីរប៊ីលាន) រៀល នៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវមូលធនភាគហ៊ុនិកយ៉ាងតិចស្មើនឹងមូលធនអប្បបរមាដូចមានចែងក្នុងប្រការនេះ។

៤-បំពេញលក្ខខណ្ឌតម្រូវធនធានមនុស្សដូចខាងក្រោម÷

ក-មាននាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់ ដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ក.** និងត្រូវបំពេញលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៣៧ នៃប្រកាសនេះ។

ខ-មានភ្នាក់ងារចែកចាយលក់មូលនិធិដែលត្រូវទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.**។ បុគ្គលដាក់ពាក្យស្នើសុំត្រូវមានចំនួនភ្នាក់ងារចែកចាយលក់មូលនិធិឱ្យសមាមាត្រទៅតាមទំហំនៃអាជីវកម្មរបស់ខ្លួន។

៥-មានអគារ និងបរិវេណដែលស្ថិតនៅទីតាំងសមស្រប និងដាច់ដោយឡែកពីអាជីវកម្មផ្សេងទៀត។

៦-មានប្រព័ន្ធ ឧបករណ៍ និងសម្ភារៈជារូបវន្តដូចមានចែងក្នុងប្រការ ៣៨ នៃប្រកាសនេះ។

៧-រៀបចំផែនការអាជីវកម្មសម្រាប់រយៈពេល ៣ (បី) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៨-មានវិធានការងារ (Working Rule) សម្រាប់គ្រប់គ្រងសកម្មភាពលក់ដូចមានចែងក្នុងប្រការ ៣៩ នៃប្រកាសនេះ។

៩-មានគោលនយោបាយសម្រាប់គ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងសមស្រប។

១០-មានគោលការណ៍ស្គាល់អតិថិជន។

១១-មានអភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមិនជាប់ពាក់ព័ន្ធនឹងចំណុចណាមួយដូចខាងក្រោម÷

- ជាអភិបាល ឬជានិយោជិតនៃក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សងផ្សេងទៀត ឬក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស
- ធ្លាប់ធ្វើជាអភិបាលរបស់ក្រុមហ៊ុនដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះ ត្រូវបានដកហូតដោយអគ្គនាយកនៃ **គ.ម.ក.** ឬដោយស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀតដែលមានអំណាចប្រហាក់ប្រហែលនឹង **គ.ម.ក.** លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

១២-មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈដូចមានចែងក្នុងចំណុច ក ដល់ ញ នៃចំណុច ទី ៥ នៃកថាខណ្ឌទី ៣ នៃប្រការ ៩ នៃប្រកាសនេះ។

## ប្រការ ៣៧.- បុគ្គលដែលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

ដើម្បីទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់ ត្រូវដាក់ពាក្យស្នើសុំមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ព្រមទាំងបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១-មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២-ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-មានសញ្ញាបត្រ និងបទពិសោធន៍ដូចខាងក្រោម÷

ក-នាយកប្រតិបត្តិ និងប្រធានប្រតិបត្តិការ ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងមានបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ។

ខ-បុគ្គលិកជំនាញផ្នែកច្បាប់ត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកច្បាប់ និងមានបទពិសោធន៍ការងារយ៉ាងតិច ១ (មួយ) ឆ្នាំ ក្នុងវិស័យហិរញ្ញវត្ថុ។

៤-ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង។

៥-បំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ១០ នៃប្រកាសនេះ។

៦-មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈដូចមានចែងក្នុងចំណុច ក ដល់ ឌ នៃចំណុចទី ៦ នៃប្រការ ១៩ នៃប្រកាសនេះ។

**ប្រការ ៣៨.- ប្រព័ន្ធ ឧបករណ៍ និងសម្ភារៈរបស់ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង**

បុគ្គលដាក់ពាក្យស្នើសុំត្រូវមានប្រព័ន្ធ ឧបករណ៍ និងសម្ភារៈដូចខាងក្រោម÷

១-រៀបចំប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ធ្វើអាជីវកម្មដែលសុំអាជ្ញាបណ្ណ/ការអនុញ្ញាតឱ្យមានលក្ខណៈស្ថិរភាព និងសុវត្ថិភាព។

២-មានប្រព័ន្ធព័ត៌មានវិទ្យាដែលមានសមត្ថភាពគ្រប់គ្រាន់អាចទទួលបញ្ជាទិញ-លក់ឯកតាមូលនិធិដែលរំពឹងទុកនាពេលអនាគត និងត្រូវធ្វើតេស្តសាកល្បងប្រព័ន្ធនោះឱ្យបានត្រឹមត្រូវ។

៣-រៀបចំវិធានការសុវត្ថិភាពដើម្បីទប់ស្កាត់សាធារណជនពីខាងក្រៅដែលមិនមានការអនុញ្ញាតឱ្យចូលក្នុងកន្លែងហាមឃាត់។

៤-ដំឡើងឱ្យបានពេញលេញនូវប្រព័ន្ធទ្រទ្រង់ និងប្រព័ន្ធដែលអាចការពារភាពលើសហួសសមត្ថភាព ឬការខូចខាត និងដែលអាចដោះស្រាយរាល់បញ្ហាដែលអាចកើតមាន។

ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សងត្រូវសហការជាមួយមន្ត្រីមានសមត្ថកិច្ចរបស់ **គ.ម.ក.** ក្នុងការបំពេញភារកិច្ចត្រួតពិនិត្យលើប្រព័ន្ធ ឧបករណ៍ និងសម្ភារៈចម្បងរបស់ក្រុមហ៊ុន។

**ប្រការ ៣៩.- វិធានការងារសម្រាប់គ្រប់គ្រងសកម្មភាពលក់**

វិធានការងារសម្រាប់គ្រប់គ្រងសកម្មភាពលក់ត្រូវមានខ្លឹមសារគោលដែលហាមឃាត់ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង និងភ្នាក់ងារលក់មូលនិធិពីការធ្វើសកម្មភាពដូចខាងក្រោម÷

១-ធានាប្រាក់ចំណេញ និងប្រាក់វិនិយោគដើមដល់អតិថិជន។

២-ទទួលកម្រៃសម្រាប់ការលក់ពីអតិថិជនដែលមិនមែនជាកម្រៃជើងសាពាក់ព័ន្ធដោយផ្ទាល់ទៅនឹងការលក់។

៣-ប្រើប្រាស់ព័ត៌មានដែលទទួលបានពាក់ព័ន្ធនឹងសកម្មភាពអាជីវកម្មលក់សម្រាប់ផលប្រយោជន៍ផ្ទាល់ខ្លួន ឬផលប្រយោជន៍របស់តតិយជន។

៤-ធ្វើការបង្ហាញព័ត៌មានខុស ឬដែលនាំឱ្យយល់ច្រឡំ។

៥-សកម្មភាពផ្សេងទៀតដែលប៉ះពាល់ផលប្រយោជន៍របស់អតិថិជន។

នៅពេលមានការកែប្រែវិធានការងារសម្រាប់គ្រប់គ្រងសកម្មភាពលក់ ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ត្រូវជូនដំណឹង និងផ្តល់ជូនមក **គ.ម.ក.** នូវវិធានការងារថ្មីក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដាក់ឱ្យអនុវត្តវិធានការងារថ្មីនេះ។

## ប្រការ ៤០.- ការតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សងត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់។ ប្រសិនបើតំណែងសម្រាប់នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់នៅទំនេរ ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សងត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៤១.- ការលុបចោលអាជ្ញាបណ្ណ/ការអនុញ្ញាតរបស់ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

អគ្គនាយកនៃ **គ.ម.ក.** អាចលុបចោលអាជ្ញាបណ្ណ/ការអនុញ្ញាតរបស់ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ក្នុងករណីក្រុមហ៊ុនស្នើសុំផ្អាក ឬឈប់ធ្វើប្រតិបត្តិការអាជីវកម្ម។

# ជំពូកទី ៥
# ភ្នាក់ងារចែកចាយលក់មូលនិធិ

## ប្រការ ៤២.- អាជ្ញាបណ្ណភ្នាក់ងារចែកចាយលក់មូលនិធិ

គ្មានបុគ្គលណាមួយអាចធ្វើជាភ្នាក់ងារចែកចាយលក់មូលនិធិ ឬតាំងខ្លួនជាភ្នាក់ងារលក់មូលនិធិបានទេ លើកលែងតែបុគ្គលនោះទទួលបានអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.**។

អាជ្ញាបណ្ណរបស់ភ្នាក់ងារចែកចាយលក់មូលនិធិមានសុពលភាព ២ (ពីរ) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ។

អាជ្ញាបណ្ណបន្តរបស់ភ្នាក់ងារចែកចាយលក់មូលនិធិមានសុពលភាព ៣ (បី) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទអាជ្ញាបណ្ណចាស់អស់សុពលភាព។

## ប្រការ ៤៣.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណភ្នាក់ងារចែកចាយលក់មូលនិធិ

បុគ្គលដែលមានបំណងធ្វើជាភ្នាក់ងារចែកចាយលក់មូលនិធិ ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ ភ្នាក់ងារចែកចាយលក់មូលនិធិត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ឱ្យបានយ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទអាជ្ញាបណ្ណចាស់អស់សុពលភាព។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់-

ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

## ប្រការ ៤៤.- លក្ខខណ្ឌតម្រូវអាជ្ញាបណ្ណភ្នាក់ងារចែកចាយលក់មូលនិធិ

ដើម្បីទទួលបានអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាភ្នាក់ងារចែកចាយលក់មូលនិធិ បុគ្គលដាក់ពាក្យស្នើសុំត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១-មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២-ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣-បំពេញលក្ខខណ្ឌយ៉ាងហោចណាស់មួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម÷

ក-មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ។

ខ-មានបទពិសោធន៍ការងារយ៉ាងតិច ២ (ពីរ) ឆ្នាំ ក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ។

៤-ផ្តល់លិខិតយល់ព្រមឱ្យធ្វើជាភ្នាក់ងារចែកចាយលក់មូលនិធិពីក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង។

៥-បំពេញលក្ខខណ្ឌដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ១០ នៃប្រកាសនេះ។

៦-មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈដូចមានចែងក្នុងចំណុចទី ៦ នៃប្រការ ១៩ នៃប្រកាសនេះ។

## ប្រការ ៤៥.- ការលុបចោលអាជ្ញាបណ្ណរបស់ភ្នាក់ងារចែកចាយលក់មូលនិធិ

អគ្គនាយកនៃ **គ.ម.ក.** អាចលុបចោលអាជ្ញាបណ្ណភ្នាក់ងារចែកចាយលក់មូលនិធិ ក្នុងករណីភ្នាក់ងារចែកចាយលក់មូលនិធិស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១-ក្លាយជាអសមត្ថជន។

២-លាឈប់ ឬផ្លាស់ប្តូរការងារ។

៣-ព្យួរការងារ ឬហេតុការណ៍ណាមួយដែលភ្នាក់ងារចែកចាយលក់មូលនិធិមិនអាចអនុវត្តការងារបាន។

# ជំពូកទី ៦

# ក្រុមហ៊ុនអភិបាលមូលនិធិ

## ប្រការ ៤៦.- អាជ្ញាបណ្ណ/ការអនុញ្ញាតក្រុមហ៊ុនអភិបាលមូលនិធិ

បុគ្គលដែលមានបំណងធ្វើជាក្រុមហ៊ុនអភិបាលមូលនិធិនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ ការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

អាជ្ញាបណ្ណ/ការអនុញ្ញាតរបស់ក្រុមហ៊ុនអភិបាលមូលនិធិមានសុពលភាព ២ (ពីរ) ឆ្នាំ គិតចាប់ពីកាល-

បរិច្ឆេទចេញអាជ្ញាបណ្ណ/ការអនុញ្ញាត។

អាជ្ញាបណ្ណ/ការអនុញ្ញាតបន្តរបស់ក្រុមហ៊ុនអភិបាលមូលនិធិមានសុពលភាព ៣ (បី) ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព។

ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ក្រុមហ៊ុនសមភាគីកណ្តាល និងឈ្មួញជើងសាឧបករណ៍និស្សន្ទដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **គ.ម.ក.** អាចដាក់ពាក្យស្នើសុំការអនុញ្ញាតបន្ថែមមក **គ.ម.ក.** ដើម្បីធ្វើអាជីវកម្មជាក្រុមហ៊ុនអភិបាលមូលនិធិ ដោយអនុលោមតាមប្រកាសនេះ។

## ប្រការ ៤៧.- អាជីវកម្មរបស់ក្រុមហ៊ុនអភិបាលមូលនិធិ

ក្រុមហ៊ុនអភិបាលមូលនិធិដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតអាចធ្វើអាជីវកម្មដូចខាងក្រោម៖

១-ផ្ទេរកម្មសិទ្ធិនៃឯកតាមូលនិធិ។

២-គណនាទ្រព្យសម្បត្តិបរធនវិនិយោគ។

៣-វាយតម្លៃទ្រព្យសកម្មសុទ្ធ និងដាក់តម្លៃឯកតាមូលនិធិ។

## ប្រការ ៤៨.- ការដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតក្រុមហ៊ុនអភិបាលមូលនិធិ

បុគ្គលដែលមានបំណងធ្វើអាជីវកម្មជាក្រុមហ៊ុនអភិបាលមូលនិធិត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

ករណីស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត ក្រុមហ៊ុនអភិបាលមូលនិធិត្រូវដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្តល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ឱ្យបានយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវចាត់ចែងការចុះត្រួតពិនិត្យដល់ទីកន្លែងដើម្បីផ្ទៀងផ្ទាត់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត និងពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាត។

អគ្គនាយកនៃ **គ.ម.ក.** ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរដល់បុគ្គលដាក់ពាក្យស្នើសុំអំពីការយល់ព្រម ឬបដិសេធផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតដូចមានចែងក្នុងកថាខណ្ឌទី ១ និងកថាខណ្ឌទី ២ នៃប្រការនេះ ក្នុងរយៈពេលយ៉ាងយូរ ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែល **គ.ម.ក.** ទទួលបានពាក្យស្នើសុំ និងឯកសារភ្ជាប់ពេញលេញ។

## ប្រការ ៤៩.- លក្ខខណ្ឌតម្រូវអាជ្ញាបណ្ណ/ការអនុញ្ញាតក្រុមហ៊ុនអភិបាលមូលនិធិ

បុគ្គលដែលដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើអាជីវកម្មជាក្រុមហ៊ុនអភិបាលមូលនិធិត្រូវបំពេញតាមលក្ខខណ្ឌដូចខាងក្រោម៖

១-ជាក្រុមហ៊ុនដែលចុះបញ្ជីពាណិជ្ជកម្មនៅព្រះរាជាណាចក្រកម្ពុជា។

២-ត្រូវចុះបញ្ជីពន្ធដារអនុលោមតាមច្បាប់ស្តីពីសារពើពន្ធ និងបទប្បញ្ញត្តិពាក់ព័ន្ធ។

៣- ត្រូវមានមូលធនអប្បបរមាចំនួន ៤០០.០០០.០០០ (បួនរយលាន) រៀល និងត្រូវដាក់ប្រាក់តម្កល់ធានាអាជីវកម្មចំនួន ១៥ (ដប់ប្រាំ) ភាគរយ នៃមូលធនអប្បបរមាក្នុងគណនីរបស់ **គ.ម.ក.** នៅធនាគារជាតិនៃកម្ពុជា។ លក្ខខណ្ឌមូលធនអប្បបរមានេះមិនអនុវត្តចំពោះបុគ្គលដាក់ពាក្យស្នើសុំដែលជាធនាគារ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ក្រុមហ៊ុនធានារ៉ាប់រង ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ក្រុមហ៊ុនមូលបត្រ ក្រុមហ៊ុនទីប្រឹក្សាហិរញ្ញវត្ថុ ក្រុមហ៊ុនទីប្រឹក្សាវិនិយោគ ក្រុមហ៊ុនសមភាគីកណ្ដាល ឈ្មួញជើងសាឧបករណ៍និស្សន្ទ ក្រុមហ៊ុនផ្ដល់សេវាសវនកម្មក្នុងវិស័យមូលបត្រ ភ្នាក់ងារបញ្ជិកាមូលបត្រ ភ្នាក់ងារចុះបញ្ជីផ្ទេរមូលបត្រ ភ្នាក់ងារទូទាត់ នៅព្រះរាជាណាចក្រកម្ពុជា។ ក្រុមហ៊ុនអភិបាលមូលនិធិត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវមូលធនភាគហ៊ុនិកយ៉ាងតិចស្មើនឹងមូលធនអប្បបរមាដូចមានចែងក្នុងប្រការនេះ។

៤- មាននាយកប្រតិបត្តិ និងគណនេយ្យករជំនាញមូលនិធិ ដែលត្រូវទទួលបានការទទួលស្គាល់គុណវុឌ្ឍិពីអគ្គនាយកនៃ **គ.ម.ក.** និងបំពេញលក្ខខណ្ឌតម្រូវដូចមានចែងនៅក្នុងប្រការ ៥០ នៃប្រកាសនេះ។

៥- មានអគារ និងបរិវេណដែលស្ថិតនៅទីតាំងសមស្រប និងដាច់ដោយឡែកពីអាជីវកម្មផ្សេងទៀត។

៦- មានប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រាន់ ឧបករណ៍ សម្ភារៈជារូបវន្តដើម្បីផ្ដល់សេវាជាក្រុមហ៊ុនអភិបាលមូលនិធិ និងត្រូវដំឡើងឱ្យបានពេញលេញនូវប្រព័ន្ធទ្រទ្រង់។

៧- មានផែនការអាជីវកម្មសម្រាប់រយៈពេល ៣ (បី) ឆ្នាំគិតចាប់ពីកាលបរិច្ឆេទដាក់ពាក្យស្នើសុំ។

៨- មានគោលនយោបាយសម្រាប់គ្រប់គ្រងហានិភ័យ និងត្រួតពិនិត្យផ្ទៃក្នុងសមស្រប។

៩- មានអភិបាល និងបុគ្គលិកជាន់ខ្ពស់ដែលមិនជាប់ពាក់ព័ន្ធនឹងចំណុចណាមួយដូចខាងក្រោម÷

- ជាអភិបាល ឬជានិយោជិតនៃក្រុមហ៊ុនអភិបាលមូលនិធិផ្សេងទៀត ឬក្រុមហ៊ុនដែលធ្វើអាជីវកម្មដែលអាចមានទំនាស់ផលប្រយោជន៍
- ធ្លាប់ធ្វើជាអភិបាលរបស់ក្រុមហ៊ុនដែលអាជ្ញាបណ្ណរបស់ក្រុមហ៊ុននោះ ត្រូវបានដកហូតដោយអគ្គនាយកនៃ **គ.ម.ក.** ឬដោយស្ថាប័នណាមួយរបស់ប្រទេសផ្សេងទៀតដែលមានអំណាចប្រហាក់ប្រហែលនឹង **គ.ម.ក.** លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

១០- មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈដូចមានចែងក្នុងចំណុច ក ដល់ ញ នៃចំណុចទី ៥ នៃកថាខណ្ឌទី ៣ នៃប្រការ ៩ នៃប្រកាសនេះ។

## ប្រការ ៥០.- បុគ្គលដែលត្រូវទទួលស្គាល់គុណវុឌ្ឍិក្នុងក្រុមហ៊ុនអភិបាលមូលនិធិ

ដើម្បីទទួលបានការទទួលស្គាល់គុណវុឌ្ឍិ នាយកប្រតិបត្តិ និងគណនេយ្យករជំនាញមូលនិធិក្នុងក្រុមហ៊ុនអភិបាលមូលនិធិ ត្រូវដាក់ពាក្យស្នើសុំមក **គ.ម.ក.** ទៅតាមទម្រង់ និងផ្ដល់ឯកសារភ្ជាប់ដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ព្រមទាំងបំពេញលក្ខខណ្ឌដូចខាងក្រោម÷

១- មានលក្ខណសម្បត្តិ និងអត្តចរិតល្អ។

២- ជាសមត្ថជន និងមានលំនៅឋានក្នុងព្រះរាជាណាចក្រកម្ពុជា។

៣- នាយកប្រតិបត្តិត្រូវមានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាពាក់ព័ន្ធនឹងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ ឬសញ្ញាបត្រផ្សេងទៀតដែលមានតម្លៃប្រហាក់ប្រហែលក្នុងវិស័យហិរញ្ញវត្ថុ និងត្រូវមានចំណេះដឹង និងមានបទពិសោធន៍ការងារយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ។

៤- គណនេយ្យករជំនាញមូលនិធិត្រូវបំពេញលក្ខខណ្ឌមួយក្នុងចំណោមលក្ខខណ្ឌដូចខាងក្រោម÷

- មានសញ្ញាបត្រយ៉ាងតិចកម្រិតឧត្តមសិក្សាផ្នែកគណនេយ្យ ឬផ្នែកពាក់ព័ន្ធ និងមានបទពិសោធន៍ការងារធ្វើជាគណនេយ្យករយ៉ាងតិច ៣ (បី) ឆ្នាំ ក្នុងវិស័យមូលបត្រ ឬហិរញ្ញវត្ថុ
- ជាគណនេយ្យករជំនាញ
- ជាអ្នកវិភាគហិរញ្ញវត្ថុជំនាញ។

៥- ផ្តល់លិខិតតែងតាំងពីក្រុមហ៊ុនអភិបាលមូលនិធិ។

៦- បំពេញលក្ខខណ្ឌដែលមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ១០ នៃប្រកាសនេះ។

៧- មិនស្ថិតនៅក្នុងស្ថានភាព ឬកាលៈទេសៈដូចមានចែងក្នុងចំណុច ក ដល់ ឌ នៃចំណុចទី ៦ នៃប្រការ ១៩ នៃប្រកាសនេះ។

**ប្រការ ៥១.- ការតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល និងបុគ្គលិកជាន់ខ្ពស់របស់ក្រុមហ៊ុនអភិបាលមូលនិធិ**

ក្រុមហ៊ុនអភិបាលមូលនិធិត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹងតែងតាំង ឬផ្លាស់ប្តូរសមាសភាពក្រុមប្រឹក្សាភិបាល នាយកប្រតិបត្តិ និងគណនេយ្យករជំនាញមូលនិធិ។ ប្រសិនបើតំណែងសម្រាប់នាយកប្រតិបត្តិ និងគណនេយ្យករ ជំនាញមូលនិធិនៅទំនេរ ក្រុមហ៊ុនអភិបាលមូលនិធិត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ២ (ពីរ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៥២.- ការលុបចោលអាជ្ញាបណ្ណ/ការអនុញ្ញាតរបស់ក្រុមហ៊ុនអភិបាលមូលនិធិ**

អគ្គនាយកនៃ **គ.ម.ក.** អាចលុបចោលអាជ្ញាបណ្ណ/ការអនុញ្ញាតក្រុមហ៊ុនអភិបាលមូលនិធិ ក្នុងករណីក្រុមហ៊ុនអភិបាលមូលនិធិស្នើសុំផ្អាក ឬឈប់ធ្វើប្រតិបត្តិការអាជីវកម្ម។

## ជំពូកទី ៧
## បទប្បញ្ញត្តិផ្សេងៗ

**ប្រការ ៥៣.- ការចាប់ផ្តើមធ្វើអាជីវកម្ម**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេលយ៉ាងយូរ ៣ (បី)

ខែគិតចាប់ពីកាលបរិច្ឆេទចេញអាជ្ញាបណ្ណ/ការអនុញ្ញាត។

**ប្រការ ៥៤.- ការបែងចែកអាជីវកម្មរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវធ្វើអាជីវកម្មដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** ដាច់ដោយឡែកពីអាជីវកម្មផ្សេងដែលខ្លួនមាន ដោយត្រូវមានទីតាំងអាជីវកម្ម បរិក្ខារ ប្រព័ន្ធព័ត៌មានវិទ្យា ធនធានមនុស្សដាច់ដោយឡែកពីគ្នា និងត្រូវមានរបាំងព័ត៌មានសមស្រប។

**ប្រការ ៥៥.- កាតព្វកិច្ចបន្តគោរពតាមលក្ខខណ្ឌ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបន្តគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ៩, ប្រការ ២៨, ប្រការ ៣៦ និងប្រការ ៤៩ នៃប្រកាសនេះ។

ភ្នាក់ងារទទួលបានអាជ្ញាបណ្ណត្រូវបន្តគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ១៩, ប្រការ ២៣ និងប្រការ ៤៤ នៃប្រកាសនេះ។

បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិត្រូវបន្តគោរពតាមលក្ខខណ្ឌដូចមានចែងក្នុងប្រការ ១០, ប្រការ ២៩, ប្រការ ៣៧ និងប្រការ ៥០ នៃប្រកាសនេះ។

**ប្រការ ៥៦.- ការលុបចោលការទទួលស្គាល់គុណវុឌ្ឍិ**

អគ្គនាយកនៃ **គ.ម.ក.** អាចលុបចោលការទទួលស្គាល់គុណវុឌ្ឍិ ក្នុងករណីបុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១- ក្លាយជាអសមត្ថជន។

២- លាឈប់ ឬផ្លាស់ប្តូរការងារ។

៣- ហេតុការណ៍ណាមួយដែលបុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិមិនអាចអនុវត្តការងារបាន។

៤- ល្មើសនឹងប្រការ ៥៥ នៃប្រកាសនេះ។

**ប្រការ ៥៧.- កាតព្វកិច្ចរក្សាកម្រិតស្ថានភាពហិរញ្ញវត្ថុ**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវរក្សាឱ្យបានគ្រប់ពេលវេលានូវកម្រិតសោធនភាព អនុបាតហានិភ័យ មូលធនសុទ្ធ និងកម្រិតស្ថានភាពហិរញ្ញវត្ថុផ្សេងទៀតដែលកំណត់ដោយ **គ.ម.ក.**។

**ប្រការ ៥៨.- ការបើក ឬបិទសាខា ឬការិយាល័យតំណាងរបស់ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត**

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលមានបំណងបើក ឬបិទសាខា ឬការិយាល័យតំណាង ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបំពេញលក្ខខណ្ឌដែលកំណត់ដោយ **គ.ម.ក.**។

### ប្រការ ៥៩.- ការជូនដំណឹងអំពីបុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ និងភ្នាក់ងារទទួលបានអាជ្ញាបណ្ណ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** អំពីការលាឈប់ ឬការបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ និងភ្នាក់ងារទទួលបានអាជ្ញាបណ្ណរបស់ខ្លួនក្នុងរយៈពេល ៧ (ប្រាំពីរ) ថ្ងៃបន្ទាប់ពីទទួលបានលិខិតលាឈប់ពីការងារ ឬការសម្រេចបញ្ចប់តួនាទី ឬការផ្លាស់ប្តូរមុខងាររបស់បុគ្គល និងភ្នាក់ងារនោះ។

### ប្រការ ៦០.- ភ្នាក់ងារគ្រប់គ្រងមូលនិធិនៅក្នុងគម្រោងវិនិយោគរួមនីមួយៗ

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវធានាថាមានភ្នាក់ងារគ្រប់គ្រងមូលនិធិដើម្បីគ្រប់គ្រង និងចាត់ចែងគម្រោងវិនិយោគរួមនីមួយៗ។

ប្រសិនតំណែងសម្រាប់ភ្នាក់ងារគ្រប់គ្រងមូលនិធិនៅក្នុងគម្រោងវិនិយោគណាមួយនៅទំនេរ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជ្រើសរើសបេក្ខភាពថ្មីក្នុងរយៈពេលយ៉ាងយូរ ១ (មួយ) ខែ គិតចាប់ពីកាលបរិច្ឆេទដែលតំណែងនោះនៅទំនេរ ឬក្នុងរយៈពេលសមស្របណាមួយដែលអនុញ្ញាតដោយអគ្គនាយកនៃ **គ.ម.ក.**។ ក្នុងអំឡុងពេលដែលតំណែងសម្រាប់ភ្នាក់ងារគ្រប់គ្រងមូលនិធិនៅទំនេរនៅក្នុងគម្រោងវិនិយោគណាមួយ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវធានាឲ្យបាននូវនិរន្តរភាពនៃការគ្រប់គ្រង និងការចាត់ចែងនៃគម្រោងវិនិយោគនោះ។

### ប្រការ ៦១.- ការចុះកិច្ចព្រមព្រៀងបរធនបាលកិច្ច

មុនបង្កើតគម្រោងវិនិយោគរួម ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវចុះកិច្ចព្រមព្រៀងបរធនបាលកិច្ចជាមួយក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស។ ទម្រង់នៃកិច្ចព្រមព្រៀងនេះត្រូវកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

### ប្រការ ៦២.- ការទទួលខុសត្រូវចំពោះសកម្មភាពរបស់ភ្នាក់ងារ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវត្រួតពិនិត្យយ៉ាងយកចិត្តទុកដាក់លើសកម្មភាពរបស់ភ្នាក់ងារដែលបំពេញមុខងារក្នុងនាមក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតនោះ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបង្កើត រក្សា និងតម្រូវឲ្យអនុវត្តនីតិវិធីជាលាយលក្ខណ៍អក្សរទាក់ទងនឹងការប្រព្រឹត្តនៃភ្នាក់ងាររបស់ខ្លួន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ដែលកើតចេញពីសកម្មភាពរបស់ភ្នាក់ងាររបស់ខ្លួន ដែលទទួលបានការអនុញ្ញាតពីក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតឲ្យធ្វើសកម្មភាពក្រោមលក្ខខណ្ឌនៃអាជ្ញាបណ្ណ/ការអនុញ្ញាត។

សកម្មភាពរបស់ភ្នាក់ងារទទួលបានអាជ្ញាបណ្ណ ដែលនាំឲ្យក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតទទួលខុសត្រូវចំពោះបណ្តឹងរដ្ឋប្បវេណី រាប់បញ្ចូលទាំងការគេចវេះ មិនចាត់វិធានការក្នុងស្ថានភាពជាក់ស្តែងណាមួយផងដែរ។

សកម្មភាពរបស់ភ្នាក់ងារទទួលបានអាជ្ញាបណ្ណ ដែលអនុញ្ញាតដោយក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/

ការអនុញ្ញាត ត្រូវគិតទាំងសកម្មភាពដែលទទួលបានការអនុញ្ញាតដោយតុណ្ហីភាព ដោយឈរលើមូលដ្ឋានដែលក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដឹង ឬគួរតែដឹងថា ភ្នាក់ងារទទួលបានអាជ្ញាបណ្ណនោះបានធ្វើសកម្មភាពនានា ហើយមិនចាត់វិធានការដើម្បីទប់ស្កាត់ ឬបដិសេធសកម្មភាពទាំងនោះ។

## ប្រការ ៦៣.- កិច្ចសន្យាចែកចាយលក់ឯកតាមូលនិធិ

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិអាចស្នើសុំការអនុញ្ញាតធ្វើអាជីវកម្មចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សងឯកតាមូលនិធិដោយផ្ទាល់ ឬអាចចុះកិច្ចសន្យាចែកចាយលក់ឯកតាមូលនិធិជាមួយក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សងដែលទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតពី **គ.ម.ក.**។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរមក **គ.ម.ក.** អំពីការចាត់តាំងក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ដោយភ្ជាប់មកជាមួយនូវកិច្ចសន្យាចែកចាយលក់ឯកតាមូលនិធិ។

ក្រុមហ៊ុនដែលធ្វើអាជីវកម្មចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ត្រូវវាយតម្លៃភាពសាកសមរបស់អតិថិជន (Investor Suitability) ចុះកិច្ចព្រមព្រៀងអតិថិជនជាមួយអតិថិជន ទទួលសេចក្តីប្រកាសទទួលស្គាល់ហានិភ័យពីអតិថិជន បើកគណនីជូនអតិថិជន និងបំពេញទម្រង់ផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។ ពាក្យស្នើសុំបើកគណនី ទម្រង់វាយតម្លៃភាពសាកសមរបស់អតិថិជន កិច្ចព្រមព្រៀងអតិថិជន និងសេចក្តីប្រកាសទទួលស្គាល់ហានិភ័យ ត្រូវកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៦៤.- មូលធនភាគហ៊ុនិករបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិមិនត្រូវប្រើប្រាស់មូលធនភាគហ៊ុនិករបស់ខ្លួន ដើម្បីវិនិយោគក្នុងគម្រោងវិនិយោគរួមដែលក្រុមហ៊ុនកំពុងគ្រប់គ្រង និងក្នុងក្រុមហ៊ុនធ្វើសំណើលក់មូលបត្រតាមរយៈអន្តរការីយកម្មរបស់ខ្លួន លើកលែងមានការអនុញ្ញាតផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៦៥.- ការផ្លាស់ប្តូរក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

មុនផ្លាស់ប្តូរក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវដាក់សំណើសុំផ្លាស់ប្តូរនេះមក **គ.ម.ក.**។

មុនទទួលបានការអនុញ្ញាតពី **គ.ម.ក.** លើសំណើសុំផ្លាស់ប្តូរក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែ-រក្សាទ្រព្យសម្បត្តិជំនួសត្រូវជូនដំណឹងអំពីសំណើសុំផ្លាស់ប្តូរនេះដល់អត្ថគាហកៈ។ អត្ថគាហកៈមានសិទ្ធិដាក់ពាក្យជំទាស់ចំពោះសំណើសុំផ្លាស់ប្តូរនេះក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង។

**គ.ម.ក.** អាចអនុញ្ញាតលើសំណើសុំផ្លាស់ប្តូរនេះ លុះត្រាតែលក្ខខណ្ឌតម្រូវ និងនីតិវិធីពាក់ព័ន្ធដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ត្រូវបានបំពេញ ហើយការផ្លាស់ប្តូរនេះមិនប៉ះពាល់ដល់ផលប្រយោជន៍របស់អត្ថគាហកៈ។

**គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចរបស់ **គ.ម.ក.** លើសំណើសុំផ្លាស់ប្តូរនេះតាមរយៈប្រព័ន្ធសារព័ត៌មាន ក្នុងករណីចាំបាច់។

**ប្រការ ៦៦.- ការផ្លាស់ប្តូរក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស**

មុនផ្លាស់ប្តូរក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ឬក្រុមហ៊ុនគ្រប់-គ្រងមូលនិធិត្រូវដាក់សំណើសុំផ្លាស់ប្តូរនេះមក **គ.ម.ក.**។

មុនទទួលបានការអនុញ្ញាតពី **គ.ម.ក.** លើសំណើសុំផ្លាស់ប្តូរក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងអំពីសំណើសុំផ្លាស់ប្តូរនេះដល់អត្ថគាហកៈ។ អត្ថគាហកៈមានសិទ្ធិដាក់ពាក្យជំទាស់ចំពោះសំណើសុំផ្លាស់ប្តូរនេះក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង។

**គ.ម.ក.** អាចអនុញ្ញាតលើសំណើសុំផ្លាស់ប្តូរនេះលុះត្រាតែលក្ខខណ្ឌតម្រូវ និងនីតិវិធីពាក់ព័ន្ធដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ត្រូវបានបំពេញ ហើយការផ្លាស់ប្តូរនេះមិនប៉ះពាល់ដល់ផលប្រយោជន៍របស់អត្ថគាហកៈ។

**គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើការផ្សព្វផ្សាយសេចក្តីសម្រេចរបស់ **គ.ម.ក.** លើសំណើសុំផ្លាស់ប្តូរនេះតាមរយៈប្រព័ន្ធសារព័ត៌មាន ក្នុងករណីចាំបាច់។

**ប្រការ ៦៧.- ការទិញឯកតាមូលនិធិត្រឡប់មកវិញ**

ក្នុងករណីមូលនិធិបើក អត្ថគាហកៈអាចស្នើឱ្យមានការទិញឯកតាមូលនិធិត្រឡប់មកវិញ និងការទូទាត់ជាសាច់ប្រាក់តាមរយៈក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ឬក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវយល់ព្រមទិញឯកតាមូលនិធិត្រឡប់មកវិញ និងទូទាត់សាច់ប្រាក់តាមសំណើរបស់អត្ថគាហកៈ ក្នុងករណីអត្ថគាហកៈបានបំពេញលក្ខខណ្ឌតម្រូវផ្សេងៗ អនុលោមតាមច្បាប់ បទ-ប្បញ្ញត្តិ និងកិច្ចព្រមព្រៀងពាក់ព័ន្ធដែលមានជាធរមាន។ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវទូទាត់សាច់ប្រាក់ក្នុងរយៈពេលដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** ទៅតាមប្រភេទគម្រោងវិនិយោគរួមនីមួយៗ។

**ប្រការ ៦៨.- កាតព្វកិច្ចទិញឯកតាមូលនិធិត្រឡប់មកវិញ**

**គ.ម.ក.** អាចតម្រូវឱ្យក្រុមហ៊ុនគ្រប់គ្រងមូលនិធិទិញឯកតាមូលនិធិត្រឡប់មកវិញ ប្រសិនបើ÷

១- ការទិញត្រឡប់មកវិញនេះជាការចាំបាច់ដើម្បីប្រឆាំងនឹងការសម្អាតប្រាក់ និងការពារកេរ្តិ៍ឈ្មោះទីផ្សារហិរញ្ញវត្ថុ។

២- អត្ថគាហកៈមិនគោរពតាមលក្ខខណ្ឌតម្រូវផ្សេងៗអនុលោមតាមច្បាប់ បទប្បញ្ញត្តិ គោលការណ៍ណែនាំ និងកិច្ចព្រមព្រៀងពាក់ព័ន្ធដែលមានជាធរមាន។

៣- ករណីផ្សេងទៀតកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

**ប្រការ ៦៩.- ឯករាជ្យភាពនៃក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស**

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវតែជាបុគ្គលឯករាជ្យ និងមិនមានទំនាក់ទំនងពិសេសជាមួយក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

**ប្រការ ៧០.- ភារកិច្ចរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មគ្រោងហ្វាន់ឌីង**

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ត្រូវបំពេញកាតព្វកិច្ចអប្បបរមាដូចខាងក្រោម÷

១- ធ្វើការសិក្សាការបំពេញកាតព្វកិច្ចតាមច្បាប់ (Due Diligence) លើក្រុមហ៊ុនមានបំណងធ្វើសំណើលក់មូលបត្រកម្មសិទ្ធិ ឬធ្វើសំណើលក់មូលបត្របំណុល រួមទាំងពិនិត្យលើលទ្ធភាពសងរបស់ក្រុមហ៊ុនមានបំណងធ្វើសំណើលក់មូលបត្របំណុល។

២- ធានាថាក្រុមហ៊ុនធ្វើសំណើលក់មូលបត្រដែលប្រើប្រាស់សេវាអន្តរការីយកម្មរបស់ក្រុមហ៊ុន មិនធ្លាប់ធ្វើសកម្មភាពល្មើសណាមួយនឹងច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

៣- ពិនិត្យតាមដានអនុលោមភាពនៃការអនុវត្តរបស់ក្រុមហ៊ុនធ្វើសំណើលក់មូលបត្រ តាមលក្ខខណ្ឌដែលកំណត់ដោយ **គ.ម.ក.**។ ក្នុងករណីក្រុមហ៊ុនគ្រប់គ្រងមូលនិធិរកឃើញថា ឬមានសេចក្តីសង្ស័យសមហេតុផលថាការធ្វើសំណើលក់មូលបត្រនឹងល្មើសនឹង ឬមិនអនុលោមតាមលក្ខខណ្ឌដែលកំណត់ដោយ **គ.ម.ក.** ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវបដិសេធផ្តល់សេវាអន្តរការីយកម្ម និងជូនដំណឹងភ្លាមមក **គ.ម.ក.**។

៤- រៀបចំឱ្យមានកិច្ចព្រមព្រៀងប្រើប្រាស់សេវាអន្តរការីយកម្មជាមួយនឹងក្រុមហ៊ុនធ្វើសំណើលក់មូលបត្រ ដោយតម្រូវជាអប្បបរមាឱ្យក្រុមហ៊ុនធ្វើសំណើលក់មូលបត្របំពេញកាតព្វកិច្ចដូចខាងក្រោម÷

   ក- បង្ហាញព័ត៌មានរបស់ក្រុមហ៊ុនគ្រប់គ្រាន់ដល់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ មុនការធ្វើសំណើលក់មូលបត្រ និងជានិរន្តរ៍បន្ទាប់ពីការធ្វើសំណើលក់មូលបត្រដើម្បីបង្ហាញដល់អតិថិជន។

   ខ- ជូនដំណឹងភ្លាមដល់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្នុងករណីមានការកែប្រែនៃព័ត៌មានដែលត្រូវបានបង្ហាញ។

   គ- ផ្តល់ព័ត៌មានដល់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ អំពីការប្រើប្រាស់សាច់ប្រាក់ដែលទទួលបានតាមរយៈការធ្វើសំណើលក់មូលបត្រតាមរយៈអន្តរការីយកម្មរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិតាមការកំណត់របស់ **គ.ម.ក.**។

៥- ធានាថារាល់ព័ត៌មានដែលផ្តល់ឱ្យដោយក្រុមហ៊ុនធ្វើសំណើលក់មូលបត្រដើម្បីបង្ហាញដល់អតិថិជនជាព័ត៌មានត្រឹមត្រូវពិតប្រាកដ និងមិនមានព័ត៌មាន ឬសេចក្តីថ្លែងណាមួយដែលមិនពិត ឬនាំឱ្យយល់ខុស ឬខ្វះខាតព័ត៌មាន ហើយព័ត៌មានទាំងនោះត្រូវបានបង្ហាញដល់អតិថិជន។

៦- ជូនដំណឹងភ្លាមដល់អតិថិជនអំពីបញ្ហា ឬការកែប្រែផ្សេងៗនៃព័ត៌មានរបស់ក្រុមហ៊ុនធ្វើសំណើលក់មូលបត្រ។

៧- ធានាថាសាច់ប្រាក់ដែលក្រុមហ៊ុនធ្វើសំណើលក់មូលបត្រមួយប្រមូលបានតាមរយៈអន្តរការីយកម្មរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវមានទំហំសរុបមិនលើសពី ៨០០.០០០.០០០ (ប្រាំបីរយលាន) រៀល គិតចាប់ពីការធ្វើសំណើលក់មូលបត្រដំបូង និងក្នុងរយៈពេល ១២ (ដប់ពីរ) ខែ គិតចាប់ពី

ការធ្វើសំណើលក់មូលបត្រនីមួយៗ ត្រូវមានទំហំមិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល។

៨- ធានាថាតម្លៃវិនិយោគរបស់អតិថិជននីមួយៗមិនលើសពី ២.០០០.០០០ (ពីរលាន) រៀល នៅក្នុងមួយក្រុមហ៊ុន និងតម្លៃវិនិយោគសរុបរបស់អតិថិជននីមួយៗមិនលើសពី ២០.០០០.០០០ (ម្ភៃលាន) រៀល ក្នុងរយៈពេល ១២ (ដប់ពីរ) ខែ លើកលែងតែអតិថិជននោះជាវិនិយោគិនគុណវុឌ្ឍិ ដែលកំណត់ដោយ **គ.ម.ក.**។

៩- វាយតម្លៃភាពសាកសមរបស់អតិថិជន ទទួលសេចក្ដីប្រកាសទទួលស្គាល់ហានិភ័យពីអតិថិជន ចុះកិច្ចព្រមព្រៀងអតិថិជនជាមួយអតិថិជន រួមទាំងបើកគណនីជូនអតិថិជន មុនពេលអតិថិជនចាប់ផ្ដើមធ្វើបរិវិសកម្មមូលបត្រ។ ពាក្យស្នើសុំបើកគណនី ទម្រង់វាយតម្លៃភាពសាកសមរបស់អតិថិជន កិច្ចព្រមព្រៀងអតិថិជន និងសេចក្ដីប្រកាសទទួលស្គាល់ហានិភ័យ ត្រូវកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

១០- ផ្ដល់ដល់អតិថិជននូវព័ត៌មានបច្ចុប្បន្នភាពដូចខាងក្រោម÷

ក- ដំណើរការ និងវិធីសាស្ត្រនៃការធ្វើបរិវិសកម្មតាមរយៈអន្តរការីយកម្មរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

ខ- ហានិភ័យពាក់ព័ន្ធនឹងប្រភេទមូលបត្រនីមួយៗដែលត្រូវបានធ្វើសំណើលក់។

គ- ព័ត៌មានអំពីសំណើលក់មូលបត្រដែលទទួលបានការអនុញ្ញាតពី **គ.ម.ក.**។

ឃ- ការដាក់កម្រិតលើតម្លៃវិនិយោគរបស់អតិថិជននីមួយៗ។

ង- សិទ្ធិលុបចោលបរិវិសកម្មមូលបត្រ។

ច- ពាក្យដាស់តឿនដែលបញ្ជាក់ថាមូលបត្រដែលត្រូវបានធ្វើសំណើលក់ មិនមានសន្ទនីយភាព ដោយមូលហេតុពុំមានទីផ្សារបន្ទាប់ ឬមានការរឹតត្បិតលើការផ្ទេរមូលបត្រ។

ឆ- នីតិវិធីនៃការដោះស្រាយវិវាទអនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

១១- ជូនដំណឹងភ្លាមដល់អតិថិជនដែលធ្វើបរិវិសកម្មមូលបត្រ នៅពេលទទួលបានទម្រង់ពាក្យស្នើសុំធ្វើបរិវិសកម្ម នូវព័ត៌មានអប្បបរមាដូចខាងក្រោម÷

ក- លក្ខណៈនៃមូលបត្រ។

ខ- តម្លៃនៃមូលបត្រ ការបង់ប្រាក់ និងកម្រៃផ្សេងៗ។

គ- ថ្ងៃសំណើលក់ ប្រសិនបើមាន។

ឃ- ឈ្មោះរបស់ក្រុមហ៊ុនធ្វើសំណើលក់មូលបត្រ។

ង- សិទ្ធិលុបចោលបរិវិសកម្មមូលបត្រ។

១២- បញ្ជាក់ទៅអតិថិជនដែលបានធ្វើបរិវិសកម្មមូលបត្រនូវព័ត៌មានអប្បបរមាដូចខាងក្រោម÷

ក- កាលបរិច្ឆេទនៃការធ្វើបរិវិសកម្មមូលបត្រ។

ខ- លក្ខណៈ ថ្លៃ និងបរិមាណនៃមូលបត្រដែលអតិថិជនធ្វើបរិវិសកម្ម។

គ-បរិមាណសរុបនៃមូលបត្រដែលត្រូវបានធ្វើសំណើលក់។

១៣-រៀបចំកម្មវិធីអប់រំអតិថិជន។

១៤-មានគោលនយោបាយ និងនីតិវិធីសម្រាប់ត្រួតពិនិត្យលក្ខខណ្ឌតម្រូវពាក់ព័ន្ធនឹងការប្រឆាំងការសម្អាតប្រាក់ និងហិរញ្ញប្បទានភេរវកម្ម។

១៥-មានគោលនយោបាយ និងនីតិវិធីសម្រាប់គ្រប់គ្រងការខកខានមិនសងបំណុលរបស់ក្រុមហ៊ុនធ្វើសំណើលក់មូលបត្រ និងសម្រាប់ទាមទារមកវិញនូវទំហំសាច់ប្រាក់ជំពាក់ជូនអតិថិជន។

### ប្រការ ៧១.- ប្រព័ន្ធរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មក្រោដហ្វាន់ឌីង

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ត្រូវមានប្រព័ន្ធដូចខាងក្រោម÷

១-ប្រព័ន្ធបង្ការមិនឱ្យបុគ្គលដទៃដែលមិនមែនជាអតិថិជន ចូលយកព័ត៌មានពាក់ព័ន្ធនឹងសំណើលក់មូលបត្រ។

២-ប្រព័ន្ធសម្រាប់ពិនិត្យអត្តសញ្ញាណ និងគុណវុឌ្ឍិរបស់អតិថិជន។

៣-ប្រព័ន្ធសម្រាប់ធ្វើតេស្តសាកល្បងចំណេះដឹងផ្នែកវិនិយោគរបស់អតិថិជន។

៤-ប្រព័ន្ធគ្រប់គ្រងសាច់ប្រាក់របស់អតិថិជនដែលបានធ្វើបរិវិសកម្មមូលបត្រ។

៥-ប្រព័ន្ធសម្រាប់បង្ហាញព័ត៌មានគ្រប់គ្រាន់ និងគួរឱ្យទុកចិត្តដល់អតិថិជន។

៦-ប្រព័ន្ធសម្រាប់ទំនាក់ទំនងរវាងអតិថិជន និងអតិថិជន ឬរវាងអតិថិជន និងក្រុមហ៊ុនធ្វើសំណើលក់មូលបត្រ និងបង្ការមិនឱ្យអតិថិជនធ្វើសំណើលក់មូលបត្ររបស់ខ្លួន។

៧-ប្រព័ន្ធរក្សាទុកព័ត៌មានពាក់ព័ន្ធនឹងសំណើលក់មូលបត្រ និងឯកសារផ្តល់ព័ត៌មានក្រោយធ្វើសំណើលក់មូលបត្រ។

៨-ប្រព័ន្ធរក្សាទុកទិន្នន័យរបស់អតិថិជន រួមទាំងការធ្វើបរិវិសកម្មរបស់អតិថិជន។

៩-ប្រព័ន្ធសម្រាប់បញ្ជូនព័ត៌មានដោយស្វ័យប្រវត្តិ។

១០-ប្រព័ន្ធទ្រទ្រង់សម្រាប់និរន្តរភាពធុរកិច្ច។

១១-ប្រព័ន្ធសម្រាប់ធ្វើការត្រួតពិនិត្យលើអនុលោមភាពនៃសេវាកម្មរបស់ខ្លួនតាមច្បាប់ស្តីពីការបោះផ្សាយ និងការជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងបទប្បញ្ញត្តិជាធរមាន ព្រមទាំងគោលការណ៍ណែនាំដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

១២-ប្រព័ន្ធដោះស្រាយពាក្យបណ្តឹងរបស់អតិថិជន។

### ប្រការ ៧២.- ការគ្រប់គ្រងទំនាស់ផលប្រយោជន៍ក្នុងក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មក្រោដ-ហ្វាន់ឌីង

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃ

ប្រកាសនេះ ត្រូវកំណត់ឱ្យបានច្បាស់ជាលាយលក្ខណ៍អក្សរនូវគោលនយោបាយស្ដីពីការបង្ការ និងការគ្រប់គ្រងនៃទំនាស់ផលប្រយោជន៍។ គោលនយោបាយនេះត្រូវទទួលបានការអនុញ្ញាតពីក្រុមប្រឹក្សាភិបាល ឬគណៈកម្មាធិការដែលចាត់តាំងដោយក្រុមប្រឹក្សាភិបាល និងត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយនៅក្នុងក្រុមហ៊ុន។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជំរុញ និងតាមដានការអនុវត្តគោលនយោបាយនេះរបស់អភិបាល នាយកប្រតិបត្តិ ប្រធានផ្នែក និងបុគ្គលិកក្នុងតំណែងគ្រប់គ្រងទាំងអស់។

ទំនាស់ផលប្រយោជន៍នេះសំដៅដល់ទំនាស់ផលប្រយោជន៍រវាងបុគ្គលដូចខាងក្រោម÷

១-រវាងអតិថិជន ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងបុគ្គលពាក់ព័ន្ធនឹងប្រតិបត្តិការអាជីវកម្ម។

២-រវាងអតិថិជន និងអតិថិជន ។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិមិនត្រូវផ្តល់ជំនួយហិរញ្ញវត្ថុដល់អតិថិជនដើម្បីវិនិយោគលើមូលបត្រដែលធ្វើសំណើលក់នោះទេ។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ភាគហ៊ុនិក អភិបាល នាយកប្រតិបត្តិ បុគ្គលិកជាន់ខ្ពស់ និងនិយោជិតរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ មិនត្រូវធ្វើបរិវិសកម្មមូលបត្រដែលធ្វើសំណើលក់តាមរយៈអន្តរការីយកម្មរបស់ក្រុមហ៊ុនផ្ទាល់ឡើយ លើកលែងមានការអនុញ្ញាតផ្សេងពីនេះដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៧៣.- ការផ្សាយពាណិជ្ជកម្មរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មក្រោមអាជ្ញាប័ណ្ណ

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ដែលមានបំណងផ្សាយពាណិជ្ជកម្ម ត្រូវរៀបចំមាតិកា និងវិធីសាស្ត្របង្ហាញសមស្រប ដើម្បីឱ្យអតិថិជនអាចទទួលបានព័ត៌មានចាំបាច់ និងមានប្រយោជន៍សម្រាប់ការប្រើប្រាស់សេវាអន្តរការីយកម្មរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬសម្រាប់ធ្វើការសម្រេចចិត្តវិនិយោគ។

ការផ្សាយពាណិជ្ជកម្មដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះត្រូវគោរពតាមលក្ខខណ្ឌដូចខាងក្រោម÷

១-មិនត្រូវមានព័ត៌មានមិនពិត ឬបំផ្លើស។

២-មិនត្រូវជំរុញអតិថិជនឱ្យប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុន ឬធ្វើការសម្រេចចិត្តវិនិយោគ។

៣-មិនត្រូវថ្លែងបញ្ជិតបញ្ចៀងពាក់ព័ន្ធនឹង ឬធានាឱ្យបាននូវប្រាក់ចំណេញពីការវិនិយោគ លើកលែងតែមានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

៤-ត្រូវមានពាក្យដាស់តឿនអំពីហានិភ័យពាក់ព័ន្ធនឹងការវិនិយោគ និងត្រូវជូនដំណឹងអំពីដំណើរការដើម្បីទទួលបានព័ត៌មានបន្ថែមអំពីសេវាកម្ម ឬការវិនិយោគ។

៥-ត្រូវមានប្រភពព័ត៌មានឱ្យបានច្បាស់លាស់ដែលមានលក្ខណៈបច្ចុប្បន្នភាព និងគួរឱ្យទុកចិត្តក្នុងករណីប្រើប្រាស់ ឬយោងព័ត៌មានដែលផ្តល់ឱ្យដោយបុគ្គលផ្សេង។

## ប្រការ ៧៤.- សកម្មភាពជំរុញការលក់របស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មក្រោមអាជ្ញាប័ណ្ណ

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃ

ប្រកាសនេះ អាចធ្វើសកម្មភាពជំរុញការលក់ដោយគោរពតាមលក្ខខណ្ឌដូចខាងក្រោម÷

១-មិនត្រូវបញ្ឆោះបញ្ឆេល ឬជំរុញអតិថិជនតាមរយៈសកម្មភាពជំរុញការលក់ដើម្បីសម្រេចចិត្តប្រើប្រាស់សេវាកម្មរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ឬធ្វើការសម្រេចចិត្តដោយមិនបានគិតពិចារណាលើព័ត៌មានមូលដ្ឋានចាំបាច់សម្រាប់ធ្វើការសម្រេចចិត្ត។

២-មិនត្រូវជាសកម្មភាពចាប់ឆ្នោតផ្សងសំណាងដើម្បីទទួលបានអំណោយ សិទ្ធិ និង/ឬអត្ថប្រយោជន៍ផ្សេងទៀត។

៣-ត្រូវមានលក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌច្បាស់លាស់ និងពេញលេញ ដើម្បីទទួលបានអំណោយ សិទ្ធិ និង/ឬអត្ថប្រយោជន៍ផ្សេងទៀត។ លក្ខណវិនិច្ឆ័យ និងលក្ខខណ្ឌទាំងនោះត្រូវមានលក្ខណៈសមស្រប យុត្តិធម៌ និងមិននាំឲ្យយល់ខុស។

៤-ត្រូវជូនដំណឹងដល់អតិថិជនក្នុងរយៈពេលសមស្រប មុនពេលធ្វើសកម្មភាពជំរុញការលក់។

## ប្រការ ៧៥.- ទំនាក់ទំនង និងការផ្តល់សេវាកម្មដល់អតិថិជនរបស់ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មក្រោដហ្វាន់ឌីង

ដើម្បីធ្វើទំនាក់ទំនងជាមួយអតិថិជន ឬផ្តល់សេវាកម្មជូនអតិថិជន ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ត្រូវផ្តល់ព័ត៌មានអំពីសេវាកម្ម និងហានិភ័យពាក់ព័ន្ធនឹងការប្រើប្រាស់សេវាកម្មដូចខាងក្រោម÷

១-ព័ត៌មានទូទៅអំពីក្រុមហ៊ុនគ្រប់គ្រងមូលនិធិ។

២-បុគ្គលិកលក្ខណៈ វិសាលភាព និងលក្ខខណ្ឌនៃសេវាកម្មដែលត្រូវផ្តល់ជូនអតិថិជន។

៣-បណ្តាញសម្រាប់ផ្តល់សេវាកម្ម និងទំនាក់ទំនង។

៤-សិទ្ធិ កាតព្វកិច្ច និងលក្ខខណ្ឌសម្រាប់អតិថិជនក្នុងការប្រើប្រាស់សេវាកម្ម។

៥-ទំនាស់ផលប្រយោជន៍ ប្រសិនបើមាន។

៦-ការអនុវត្តរវាងក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងអតិថិជន អនុលោមតាមច្បាប់ បទប្បញ្ញត្តិ និងគោលការណ៍ណែនាំពាក់ព័ន្ធ។

ក្នុងករណីមានការផ្លាស់ប្តូរព័ត៌មានដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវជូនដំណឹងអំពីការផ្លាស់ប្តូរនេះទៅអតិថិជនឲ្យបានមុនការធ្វើបរិវិសកម្មមូលបត្រ។

## ប្រការ ៧៦.- តេស្តសាកល្បងចំណេះដឹងវិនិយោគ

មុនការធ្វើបរិវិសកម្មមូលបត្រ ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ត្រូវធ្វើតេស្តសាកល្បងចំណេះដឹងវិនិយោគរបស់អតិថិជន លើកលែងអតិថិជនដូចខាងក្រោម÷

១-អតិថិជនដែលជាវិនិយោគិនស្ថាប័នដែលកំណត់ដោយ **គ.ម.ក.**។

២-អតិថិជនដែលជាវិនិយោគិនធនវុឌ្ឍិដែលកំណត់ដោយ **គ.ម.ក.**។

៣-អតិថិជនដែលបានធ្វើតេស្តសាកល្បងចំណេះដឹងផ្នែកវិនិយោគមិនលើសពី ៣ (បី) ខែមុនបរិវិស-កម្ម។

ការធ្វើតេស្តសាកល្បងចំណេះដឹងវិនិយោគដូចមានចែងក្នុងកថាខណ្ឌទី ១ នៃប្រការនេះ ត្រូវមានយ៉ាង-ហោចណាស់សំណួរពាក់ព័ន្ធនឹងបញ្ហាដូចខាងក្រោម÷

១-ហានិភ័យធុរកិច្ចរបស់ក្រុមហ៊ុនធ្វើសំណើលក់មូលបត្រ។

២-ហានិភ័យកើតឡើងនៅពេលក្រុមហ៊ុនធ្វើសំណើលក់មូលបត្រត្រូវបានជម្រះបញ្ជី។

៣-សន្ទនីយភាពនៃមូលបត្រដែលត្រូវបានធ្វើសំណើលក់។

៤-ការទូទាត់ភាគលាភ ការប្រាក់ និង/ ឬអត្ថប្រយោជន៍។

៥-ការបែងចែកប្រាក់ចំណេញ និងសិទ្ធិបោះឆ្នោតរបស់ភាគហ៊ុនិក។

៦-ការពិនិត្យព័ត៌មាន និងលក្ខណៈនៃសំណើលក់មូលបត្រ។

៧-ការទទួលខុសត្រូវរបស់អតិថិជនដោយខ្លួនឯង ក្នុងករណីក្រុមហ៊ុនធ្វើសំណើលក់មូលបត្របានបង្ហាញព័ត៌មានមិនពិត ឬមិនពេញលេញ។

៨-បញ្ហាផ្សេងទៀតដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.**។

## ប្រការ ៧៧.- ការបែងចែកតួនាទីភ្នាក់ងារក្រោមហ្វាន់ឌីង

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិធ្វើអាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ត្រូវបែងចែកឱ្យដាច់ពីគ្នានូវតួនាទីភ្នាក់ងារក្រោមហ្វាន់ឌីងសម្រាប់ផ្តល់សេវាកម្មដល់ក្រុមហ៊ុនធ្វើសំណើលក់មូលបត្រ និងភ្នាក់ងារក្រោមហ្វាន់ឌីងសម្រាប់ផ្តល់សេវាកម្មដល់អតិថិជនដែលជាវិនិយោគិន។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុនធ្វើការបែងចែក ឬកែប្រែការបែងចែកតួនាទីភ្នាក់ងារក្រោមហ្វាន់ឌីង។

## ប្រការ ៧៨.- ការជូនដំណឹងអំពីការកែប្រែឯកសារ ឬព័ត៌មាន

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ ការអនុញ្ញាត ភ្នាក់ងារទទួលបានអាជ្ញាបណ្ណ និងបុគ្គលដាក់ពាក្យស្នើសុំត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាបន្ទាន់មក **គ.ម.ក.** ក្នុងករណីមានការកែប្រែឯកសារ ឬព័ត៌មានពាក់-ព័ន្ធនឹងពាក្យស្នើសុំអាជ្ញាបណ្ណ/ ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ ការអនុញ្ញាត។

## ប្រការ ៧៩.- ការកែប្រែបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ/ការអនុញ្ញាត

ករណីមានការកែប្រែបទប្បញ្ញត្តិពាក់ព័ន្ធនឹងការផ្តល់អាជ្ញាបណ្ណ/ ការអនុញ្ញាតក្នុងអំឡុងពេលកំពុងពិនិត្យពាក្យស្នើសុំអាជ្ញាបណ្ណ/ ការអនុញ្ញាត ឬពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ ការអនុញ្ញាត បទប្បញ្ញត្តិថ្មីនេះត្រូវអនុវត្តចំពោះពាក្យស្នើសុំដែលកំពុងពិនិត្យនោះ។

### ប្រការ ៨០.- ភាតព្វកិច្ចស្នើសុំការអនុញ្ញាតលើការប្រើប្រាស់ ការផ្លាស់ប្តូរ ឬការកែប្រែ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវស្នើសុំការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.** មុននឹង÷

- ផ្លាស់ប្តូរ ឬកែប្រែសមាសភាពក្រុមប្រឹក្សាភិបាល រចនាសម្ព័ន្ធភាគហ៊ុនិក ដើមទុន នាមករណ៍ ឬទី-ស្នាក់ការ
- ប្រើប្រាស់ ឬកែប្រែថ្លៃសេវា ឬកម្រៃជើងសាផ្សេងៗ។

### ប្រការ ៨១.- ភាតព្វកិច្ចផ្តល់របាយការណ៍

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវដាក់ជូន **គ.ម.ក.** នូវរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំដែលត្រូវបានធ្វើសវនកម្មរួច ក្នុងរយៈពេលយ៉ាងយូរ ៣ (បី) ខែ ឬក្នុងរយៈពេលសមស្របណាមួយដែលកំណត់ដោយអគ្គនាយកនៃ **គ.ម.ក.** បន្ទាប់ពីបញ្ចប់ឆ្នាំសារពើពន្ធនីមួយៗ និងរបាយការណ៍សមាជិក ព្រមទាំងរបាយការណ៍ផ្សេងទៀតតាមការកំណត់របស់អគ្គនាយកនៃ **គ.ម.ក.**។

បន្ថែមលើលក្ខខណ្ឌខាងលើនេះ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវរៀបចំរបាយការណ៍ហិរញ្ញវត្ថុនៃទ្រព្យសម្បត្តិបរធនវិនិយោគ ឲ្យដាច់ដោយឡែកពីទ្រព្យសម្បត្តិរបស់ក្រុមហ៊ុនអនុលោមតាមស្តង់ដារគណ-នេយ្យដូចមានកំណត់ក្នុងបទប្បញ្ញត្តិជាធរមាន។

### ប្រការ ៨២.- ការផ្តល់មុខងារដល់តតិយជន

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសមិនអាចផ្តល់មុខងារដល់តតិយជនបានទេ លើកលែងតែទទួលបានការអនុញ្ញាតពីអគ្គនាយកនៃ **គ.ម.ក.**។

ក្រុមហ៊ុនគ្រប់គ្រងមូលនិធិ និងក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសត្រូវទទួលខុសត្រូវចំពោះរាល់សកម្មភាពរបស់បុគ្គលដែលទទួលមុខងារខាងក្រៅ។

ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួសដែលមានបំណងផ្តល់មុខងារដូចមានចែងក្នុងចំណុចទី ១ នៃប្រការ ២៦ នៃប្រកាសនេះ ទៅឱ្យភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រណាមួយ ត្រូវស្នើសុំការអនុញ្ញាតជាមុនពីអគ្គនាយកនៃ **គ.ម.ក.**។ ភ្នាក់ងាររក្សាសុវត្ថិភាពក្នុងវិស័យមូលបត្រដែលមានបំណងធ្វើអាជីវកម្មជាក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ត្រូវដាក់ពាក្យស្នើសុំអាជ្ញាបណ្ណពីអគ្គនាយកនៃ **គ.ម.ក.** ដោយត្រូវបំពេញតាមលក្ខខណ្ឌតម្រូវ និងនីតិវិធីអនុលោមតាមប្រកាសនេះ។

### ប្រការ ៨៣.- ការចុះត្រួតពិនិត្យដល់ទីកន្លែង

អគ្គនាយកនៃ **គ.ម.ក.** អាចចាត់មន្ត្រីជំនាញឲ្យចុះត្រួតពិនិត្យដល់ទីកន្លែងក្រុមហ៊ុនទទួលបានអាជ្ញា-បណ្ណ/ការអនុញ្ញាត ដើម្បីពិនិត្យការអនុវត្តតាមលក្ខខណ្ឌអាជ្ញាបណ្ណ/ការអនុញ្ញាត ប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុន សកម្មភាពរបស់បុគ្គលទទួលបានការទទួលស្គាល់គុណវុឌ្ឍិ និងភ្នាក់ងារទទួលបានអាជ្ញាបណ្ណ អនុលោមតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវផ្តល់កិច្ចសហការ ឯកសារ និង/ឬព័ត៌មានដល់មន្ត្រី

នៃ **គ.ម.ក.** ដែលត្រូវចាត់តាំងដោយអគ្គនាយកនៃ **គ.ម.ក.** ដើម្បីចុះត្រួតពិនិត្យដល់ទីកន្លែង។

## ជំពូកទី ៨
## កម្រៃ

### ប្រការ ៨៤.- សោហ៊ុយនៃការផ្ទេរភាគហ៊ុន

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបង់សោហ៊ុយនៃការផ្ទេរភាគហ៊ុនចំនួន ០,៥ (សូន្យក្បៀសប្រាំ) ភាគរយនៃភាគហ៊ុនដែលបានផ្ទេរ ឬស្មើនឹង ៤០.០០០.០០០ (សែសិបលាន) រៀលក្នុងករណីដែលធំជាងនេះ។

សោហ៊ុយនៃការផ្ទេរភាគហ៊ុនក្នុងកថាខណ្ឌទី ១ នៃប្រការនេះមិនអនុវត្តចំពោះក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលបានបោះផ្សាយលក់មូលបត្រជាសាធារណៈ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបង់សោហ៊ុយដូចមានចែងក្នុងប្រការនេះ នៅពេលដាក់ពាក្យស្នើសុំការអនុញ្ញាតផ្ទេរភាគហ៊ុននៅ **គ.ម.ក.**។

សោហ៊ុយនេះមិនត្រូវបានប្រគល់ជូនក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតវិញឡើយ ទោះបីជាការស្នើសុំការអនុញ្ញាតផ្ទេរភាគហ៊ុននេះត្រូវបានបដិសេធក៏ដោយ។

### ប្រការ ៨៥.- សោហ៊ុយនៃការបង្កើន និងបន្ថយដើមទុន

រាល់ការបង្កើន ឬបន្ថយដើមទុន ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបង់សោហ៊ុយចំនួន ០,០៣ (សូន្យក្បៀសសូន្យបី) ភាគរយ នៃចំនួនទឹកប្រាក់ដែលសុំបង្កើន ឬបន្ថយ។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបង់សោហ៊ុយដូចមានចែងក្នុងប្រការនេះ នៅពេលដាក់ពាក្យស្នើសុំការអនុញ្ញាតបង្កើន ឬបន្ថយដើមទុននៅ **គ.ម.ក.**។

សោហ៊ុយនេះមិនត្រូវបានប្រគល់ជូនក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតវិញឡើយ ទោះបីជាការស្នើសុំការអនុញ្ញាតបង្កើន ឬបន្ថយដើមទុនត្រូវបានបដិសេធក៏ដោយ។

### ប្រការ ៨៦.- ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃអាជ្ញាបណ្ណ/ការអនុញ្ញាត

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃពាក្យស្នើសុំ សោហ៊ុយសិក្សាសំណុំលិខិត និងថ្លៃអាជ្ញាបណ្ណ/ការអនុញ្ញាត ទៅតាមករណីដូចខាងក្រោម÷

១-ចំពោះការស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើអាជីវកម្មជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ

- ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិត÷
    - សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ១ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ចំនួន ២.០០០.០០០ (ពីរលាន) រៀល

- សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ២ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ចំនួន ១.០០០.០០០(មួយលាន) រៀល
- សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ៣ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ចំនួន ១.០០០.០០០(មួយលាន) រៀល
- សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ៤ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ចំនួន ៨០០.០០០(ប្រាំបីរយពាន់) រៀល
- សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ចំនួន ៨០០.០០០(ប្រាំបីរយពាន់) រៀល

- ថ្លៃអាជ្ញាបណ្ណ÷
  - សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ១ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ចំនួន ៤០.០០០.០០០(សែសិបលាន) រៀល សម្រាប់រយៈពេល ២(ពីរ) ឆ្នាំដំបូង និង ៦០.០០០.០០០(ហុកសិបលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ៣(បី) ឆ្នាំ
  - សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ២ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ចំនួន ២០.០០០.០០០(ម្ភៃលាន) រៀល សម្រាប់រយៈពេល ២(ពីរ) ឆ្នាំដំបូង និង ៣០.០០០.០០០(សាមសិបលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈ-ពេល ៣(បី) ឆ្នាំ
  - សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ៣ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ចំនួន ១៦.០០០.០០០(ដប់ប្រាំមួយលាន) រៀល សម្រាប់រយៈពេល ២(ពីរ) ឆ្នាំដំបូង និង ២៤.០០០.០០០(ម្ភៃបួនលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ៣(បី) ឆ្នាំ
  - សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ៤ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ចំនួន ១០.០០០.០០០(ដប់លាន) រៀល សម្រាប់រយៈពេល ២(ពីរ) ឆ្នាំដំបូង និង ១៥.០០០.០០០(ដប់ប្រាំលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ៣(បី) ឆ្នាំ
  - សម្រាប់អាជីវកម្មដូចមានចែងក្នុងចំណុចទី ៥ នៃកថាខណ្ឌទី ១ នៃប្រការ ៧ នៃប្រកាសនេះ ចំនួន ១០.០០០.០០០(ដប់លាន) រៀល សម្រាប់រយៈពេល ២(ពីរ) ឆ្នាំដំបូង និង ១៥.០០០.០០០(ដប់ប្រាំលាន) រៀល សម្រាប់ការបន្តអាជ្ញាបណ្ណរយៈពេល ៣(បី)ឆ្នាំ។

២- ចំពោះការស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើអាជីវកម្មជាក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស

- ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ២.០០០.០០០ (ពីរលាន) រៀល
- ថ្លៃអាជ្ញាបណ្ណចំនួន ៤០.០០០.០០០ (សែសិបលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និងថ្លៃអាជ្ញាបណ្ណបន្តចំនួន ៦០.០០០.០០០ (ហុកសិបលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

៣- ចំពោះការស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើអាជីវកម្មជាក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង

- ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ៨០០.០០០ (ប្រាំបីរយពាន់) រៀល
- ថ្លៃការអនុញ្ញាតចំនួន ៦.០០០.០០០ (ប្រាំមួយលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និងថ្លៃការអនុញ្ញាតបន្តចំនួន ៩.០០០.០០០ (ប្រាំបួនលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។
- ថ្លៃអាជ្ញាបណ្ណចំនួន ១៦.០០០.០០០ (ដប់ប្រាំមួយលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និងថ្លៃអាជ្ញាបណ្ណបន្តចំនួន ២៤.០០០.០០០ (ម្ភៃបួនលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

៤- ចំពោះការស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាត ឬបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតធ្វើអាជីវកម្មជាក្រុមហ៊ុនអភិបាលមូលនិធិ

- ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណ/ការអនុញ្ញាតចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល
- ថ្លៃការអនុញ្ញាតចំនួន ២.០០០.០០០ (ពីរលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និងថ្លៃការអនុញ្ញាតបន្តចំនួន ៣.០០០.០០០ (បីលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។
- ថ្លៃអាជ្ញាបណ្ណចំនួន ៨.០០០.០០០ (ប្រាំបីលាន) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និងថ្លៃអាជ្ញាបណ្ណបន្តចំនួន ១២.០០០.០០០ (ដប់ពីរលាន) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

៥- ចំពោះការស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាភ្នាក់ងារគ្រប់គ្រងមូលនិធិ

- ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ២០០.០០០ (ពីររយពាន់) រៀល
- ថ្លៃអាជ្ញាបណ្ណចំនួន ៨០០.០០០ (ប្រាំបីរយពាន់) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និងថ្លៃអាជ្ញាបណ្ណបន្តចំនួន ១.២០០.០០០ (មួយលានពីររយពាន់) រៀល សម្រាប់រយៈពេល

៣ (បី) ឆ្នាំ។

៦-ចំពោះការស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាភ្នាក់ងារក្រោដហ្វាន់ឌីង

- ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ៨០.០០០ (ប៉ែតសិបពាន់) រៀល
- ថ្លៃអាជ្ញាបណ្ណចំនួន ៤០០.០០០ (បួនរយពាន់) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និងថ្លៃអាជ្ញាបណ្ណបន្តចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

៧-ចំពោះការស្នើសុំអាជ្ញាបណ្ណ ឬបន្តអាជ្ញាបណ្ណធ្វើជាភ្នាក់ងារចែកចាយលក់មូលនិធិ

- ថ្លៃពាក្យស្នើសុំអាជ្ញាបណ្ណចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០០.០០០ (មួយរយពាន់) រៀល
- ថ្លៃអាជ្ញាបណ្ណចំនួន ៤០០.០០០ (បួនរយពាន់) រៀល សម្រាប់រយៈពេល ២ (ពីរ) ឆ្នាំដំបូង និងថ្លៃអាជ្ញាបណ្ណបន្តចំនួន ៦០០.០០០ (ប្រាំមួយរយពាន់) រៀល សម្រាប់រយៈពេល ៣ (បី) ឆ្នាំ។

៨-ចំពោះការស្នើសុំការទទួលស្គាល់គុណវុឌ្ឍិរបស់អភិបាល នាយកប្រតិបត្តិ សមាជិកគណៈកម្មាធិការវិនិយោគ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់ក្នុងក្រុមហ៊ុនគ្រប់គ្រងមូលនិធិ អភិបាល នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ បុគ្គលិកជំនាញផ្នែកច្បាប់ និងគណនេយ្យករជំនាញមូលនិធិក្នុងក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស នាយកប្រតិបត្តិ ប្រធានប្រតិបត្តិការ និងបុគ្គលិកជំនាញផ្នែកច្បាប់ក្នុងក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង និង នាយកប្រតិបត្តិ និងគណនេយ្យករជំនាញមូលនិធិក្នុងក្រុមហ៊ុនអភិបាលមូលនិធិ

- ថ្លៃពាក្យស្នើសុំការទទួលស្គាល់គុណវុឌ្ឍិចំនួន ២០.០០០ (ម្ភៃពាន់) រៀល ក្នុងមួយច្បាប់
- សោហ៊ុយសិក្សាសំណុំលិខិតចំនួន ១០០.០០០ (មួយរយពាន់) រៀល។

បុគ្គលដាក់ពាក្យស្នើសុំត្រូវបង់ថ្លៃពាក្យស្នើសុំ និងសោហ៊ុយសិក្សាសំណុំលិខិតនៅពេលដាក់ពាក្យស្នើ-សុំនៅ **គ.ម.ក.**។

ថ្លៃពាក្យស្នើសុំនិងសោហ៊ុយសិក្សាសំណុំលិខិតអនុលោមតាមប្រកាសនេះ មិនត្រូវបានប្រគល់ឱ្យបុគ្គលដាក់ពាក្យស្នើសុំវិញឡើយ ទោះបីជាការស្នើសុំត្រូវបានបដិសេធក៏ដោយ។

### ប្រការ ៨៧.- សោហ៊ុយលើការស្នើសុំការអនុញ្ញាតលើការប្រើប្រាស់ ផ្លាស់ប្តូរ ឬកែប្រែផ្សេងៗ

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតត្រូវបង់សោហ៊ុយលើការស្នើសុំការអនុញ្ញាតលើការប្រើ-ប្រាស់ ការផ្លាស់ប្តូរ ឬការកែប្រែដូចមានចែងក្នុងប្រការ ៨០ នៃប្រកាសនេះ ចំនួន ១៥០.០០០ (មួយរយហាសិបពាន់) រៀល នៅ **គ.ម.ក.** នៅពេលដាក់ពាក្យស្នើសុំ លើកលែងតែសោហ៊ុយនៃការផ្ទេរភាគហ៊ុន និង

សោហ៊ុយនៃការបង្កើន និងបន្ថយដើមទុន ដែលត្រូវអនុវត្តតាមប្រការ ៨៤ និងប្រការ ៨៥ នៃប្រកាសនេះ។

## ជំពូកទី ៩

## ទោសប្បញ្ញត្តិ

### ប្រការ ៨៨.- ការធ្វើអាជីវកម្មដោយគ្មានអាជ្ញាបណ្ណ/ការអនុញ្ញាត

បុគ្គលណាដែលធ្វើអាជីវកម្ម ឬតាំងខ្លួនជាក្រុមហ៊ុនគ្រប់គ្រងមូលនិធិ ក្រុមហ៊ុនថែរក្សាទ្រព្យសម្បត្តិជំនួស ក្រុមហ៊ុនចែកចាយលក់ ទិញត្រឡប់មកវិញ ឬទូទាត់សង ក្រុមហ៊ុនអភិបាលមូលនិធិ ភ្នាក់ងារគ្រប់គ្រងមូលនិធិ ភ្នាក់ងារក្រោជហ្វាន់ឌីង និងភ្នាក់ងារចែកចាយលក់មូលនិធិ ដោយគ្មានអាជ្ញាបណ្ណ/ការអនុញ្ញាត ឬអាជ្ញាបណ្ណ/ការអនុញ្ញាតអស់សុពលភាព ត្រូវចាត់ទុកថាជាការធ្វើអាជីវកម្មមូលបត្រដោយគ្មានអាជ្ញាបណ្ណ/ការអនុញ្ញាត និងត្រូវផ្តន្ទាទោសតាមច្បាប់ និងបទប្បញ្ញត្តិជាធរមាន។

### ប្រការ ៨៩.- ពិន័យអន្តរការណ៍

ដោយមិនគិតពីទោសទណ្ឌផ្សេងទៀតដូចមានចែងក្នុងច្បាប់ និងបទប្បញ្ញត្តិជាធរមានក្នុងព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាត និងភ្នាក់ងារទទួលបានអាជ្ញាបណ្ណ ព្រមទាំងបុគ្គលពាក់ព័ន្ធដែលល្មើសនឹងប្រការ ៩, ប្រការ ១០, ប្រការ ១៤, ប្រការ ១៩, ប្រការ ២៣, ប្រការ ២៨, ប្រការ ២៩, ប្រការ ៣១, ប្រការ ៣៦, ប្រការ ៣៧, ប្រការ ៤០, ប្រការ ៤៤, ប្រការ ៤៩, ប្រការ ៥០, ប្រការ ៥១, ប្រការ ៥៥, ប្រការ ៥៧, ប្រការ ៥៩, ប្រការ ៦០, ប្រការ ៦២, កថាខណ្ឌទី ២ និងកថាខណ្ឌទី ៣ នៃប្រការ ៦៣, ប្រការ ៦៤, ប្រការ ៦៥, ប្រការ ៦៦, កថាខណ្ឌទី២ នៃប្រការ ៦៧, ប្រការ ៦៩, ប្រការ ៧០, ប្រការ ៧១, ប្រការ ៧២, ប្រការ ៧៣, ប្រការ ៧៤, ប្រការ ៧៥, ប្រការ ៧៦, ប្រការ ៧៧, ប្រការ ៧៨, ប្រការ ៨០, ប្រការ ៨១, ប្រការ ៨២, ប្រការ ៨៣ នៃប្រកាសនេះ ឬមិនគោរពតាមការណែនាំរបស់អគ្គនាយកនៃ **គ.ម.ក.** ត្រូវទទួលទណ្ឌកម្មដូចមានចែងក្នុងប្រការ ៩០ នៃប្រកាសនេះ និង/ឬពិន័យអន្តរការណ៍ពី **គ.ម.ក.** ជាសាច់ប្រាក់ដូចខាងក្រោម÷

១-មិនលើសពី ៥០.០០០.០០០ (ហាសិបលាន) រៀល ចំពោះរូបវន្តបុគ្គល។

២-មិនលើសពី ២០០.០០០.០០០ (ពីររយលាន) រៀល ចំពោះនីតិបុគ្គល។

ក្រុមហ៊ុនទទួលបានអាជ្ញាបណ្ណ/ការអនុញ្ញាតដែលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណ/ការអនុញ្ញាតមក **គ.ម.ក.** តិចជាង ៦០ (ហុកសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណ/ការអនុញ្ញាតចាស់អស់សុពលភាព ក្រុមហ៊ុននោះត្រូវទទួលពិន័យអន្តរកាណ៍ពី **គ.ម.ក.** ជាសាច់ប្រាក់ចំនួន ១.០០០.០០០ (មួយលាន) រៀល ក្នុង ១ (មួយ) ថ្ងៃ ចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះ។

ភ្នាក់ងារទទួលបានអាជ្ញាបណ្ណដែលដាក់ពាក្យស្នើសុំបន្តអាជ្ញាបណ្ណមក **គ.ម.ក.** តិចជាង ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទដែលអាជ្ញាបណ្ណចាស់អស់សុពលភាព បុគ្គលនោះត្រូវទទួលពិន័យអន្តរកាណ៍ពី **គ.ម.ក.**

ជាសាច់ប្រាក់ចំនួន ៤០០.០០០ (បួនរយពាន់) រៀល ក្នុង ១ (មួយ) ថ្ងៃ ចំពោះការដាក់ពាក្យស្នើសុំយឺតយ៉ាវនេះ។

**ប្រការ ៩០.- ទណ្ឌកម្មរដ្ឋបាល**

អគ្គនាយកនៃ **គ.ម.គ.** អាចដាក់ទណ្ឌកម្មរដ្ឋបាលដូចខាងក្រោម÷

១- ព្រមាន។

២- ដឹកនាំកែតម្រង់។

៣- ដាក់កំហិតលើអាជ្ញាបណ្ណ/ ការអនុញ្ញាត។

៤- ព្យួរអាជ្ញាបណ្ណ/ ការអនុញ្ញាត។

៥- ដកហូតអាជ្ញាបណ្ណ/ ការអនុញ្ញាត។

**ប្រការ ៩១.- ការព្យួរ ឬការដកហូតអាជ្ញាបណ្ណ/ការអនុញ្ញាត**

អគ្គនាយកនៃ **គ.ម.គ.** អាចព្យួរ ឬដកហូតអាជ្ញាបណ្ណ/ ការអនុញ្ញាត ក្នុងករណីក្រុមហ៊ុនអាជ្ញាបណ្ណ/ ការអនុញ្ញាត និងភ្នាក់ងារទទួលបានអាជ្ញាបណ្ណស្ថិតក្នុងស្ថានភាពណាមួយដូចខាងក្រោម÷

១- មិនអាចគោរព ឬបន្តគោរពតាមលក្ខខណ្ឌតម្រូវអាជ្ញាបណ្ណ/ ការអនុញ្ញាតដូចមានចែងក្នុងប្រកាសនេះ។

២- មិនអាចអនុវត្តសេចក្តីសម្រេចដែលត្រូវឱ្យសងបំណុលមួយភាគ ឬទាំងស្រុង។

៣- កំពុងស្ថិតនៅក្នុងស្ថានភាពបច្ចេកទេស និង/ ឬហិរញ្ញវត្ថុទន់ខ្សោយមិនអាចបន្តធ្វើអាជីវកម្មបាន ឬត្រូវបានរំលាយដោយសេចក្តីសម្រេចរបស់តុលាការ។

## ជំពូកទី ១០

## អវសានប្បញ្ញត្តិ

**ប្រការ ៩២.- គោលការណ៍ណែនាំ**

អគ្គនាយកនៃ **គ.ម.គ.** អាចចេញគោលការណ៍ណែនាំ អនុលោមតាមច្បាប់ស្តីពីការបោះផ្សាយ និងជួញដូរមូលបត្រមហាជន អនុក្រឹត្យ និងប្រកាសនេះ ដើម្បីសម្រួលដល់ការយល់ដឹង និងការអនុវត្តតាមប្រកាសនេះ។

**ប្រការ ៩៣.- បដិវាទកម្ម**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៩៤.- ការអនុវត្ត**

អគ្គនាយកនៃ **គ.ម.គ.** ប្រធាននាយកដ្ឋានត្រួតពិនិត្យអន្តរការីមូលបត្រ ប្រធាននាយកដ្ឋានកិច្ចការ

គតិយុត្ត គ្រប់ប្រធាននាយកដ្ឋាន-អង្គភាពស្ថិតនៅចំណុះឲ្យ **គ.ម.ក.** និងបុគ្គលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ អង្គារ ១៥កើត ខែពិសាខ ឆ្នាំច សំរិទ្ធិស័ក ព.ស. ២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**និងជាប្រធានគណៈកម្មការមូលបត្រកម្ពុជា**

**អគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងពាណិជ្ជកម្ម
- ក្រសួងយុត្តិធម៌
- ធនាគារជាតិនៃកម្ពុជា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា
- ខុទ្ទកាល័យឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី "ដើម្បីជូនជ្រាប"
- ដូចប្រការ ៩៨ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ